នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស(អបជ__) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាជាតិ |
| ភាសាដើម | : | ខ្មែរ |

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Apr-2019, 14:03
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៣

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**សហមេធាវី មាស មុត:**
អាង ឧត្តម
Michael KARNAVAS

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ទាំងអស់នៃសំណុំរឿង០០៣**

# I. សេចក្ដីផ្ដើម

1. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរ ដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ **មាស មុត** ដោយមូលហេតុថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ **មាស មុត**[1]។ ចំណែកឯសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)[2]។

2. ដីកាដំណោះស្រាយទាំងពីរនេះ ដែលមួយជាដីកាសម្រេចលើកលែងចោទប្រកាន់ **មាស មុត** ចេញតែជាភាសាខ្មែរដោយសហចៅក្រមស៊ើបអង្កេតជាតិ និងមានការបកប្រែជាភាសាអង់គ្លេសតាមក្រោយ[3]។ ចំពោះដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចេញតែជាភាសាអង់គ្លេស ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមានការបកប្រែជាភាសាខ្មែរតាមក្រោយ[4]។

3. អនុលោមតាមសេចក្ដីណែនាំអនុវត្តបានចែងថា គ្រប់ឯកសារទាំងអស់ត្រូវដាក់ជាភាសាខ្មែររួមជាមួយភាសាអង់គ្លេស ឬបារាំង។ នៅក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យភាគីណាមួយដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែបន្ទាប់មកភាគីត្រូវដាក់ឯកសារជាភាសាខ្មែរ ដែលបានបកប្រែរួចឱ្យបានឆាប់រហ័សបំផុត។[5]

4. នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើសុំបន្ថែមពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង00៣[6]។ ឆ្លើយតបនឹងសំណើសុំនេះ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យភាគីដាក់បណ្ដឹងឧទ្ធរណ៍នឹងដីកាដំណោះ

---

[1] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ **មាស មុត** របស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[2] ឯកសារ **D267** ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[3] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ **មាស មុត** របស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយបានជូនដំណឹងអំពីការបកប្រែជាភាសាអង់គ្លេសរួចរាល់ នៅថ្ងៃទី0៦ ខែកុម្ភៈ ឆ្នាំ២០១៩។

[4] ឯកសារ **D267** ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយបានជូនដំណឹងអំពីការបកប្រែជាភាសាខ្មែររួចរាល់ នៅថ្ងៃទី0៦ ខែកុម្ភៈ ឆ្នាំ២០១៩។

[5] សេចក្ដីណែនាំអនុវត្តឱ្យដាក់ឯកសារសម្រាប់ប្រើនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, មាត្រា ៧.១ និង ៧.២។

[6] ឯកសារ **D267/1/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ **មាស មុត** សុំបន្ថែមពេលវេលាកំណត់ និងចំនួនទំព័រ សម្រាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង00៣។

ស្រាយក្នុងសំណុំរឿង០០៣ នៅក្នុងរយៈពេល ៦០ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ[7]។

5. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។[8]

6. អនុលោមតាមវិធានផ្ទៃក្នុង[9] វិធាន ៦៧(៥)[10], ៧៣(ក)[11] និង ៧៤(២)[12] សហព្រះរាជអាជ្ញាជាតិ ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានសម្រេចចេញដីកាបញ្ជូន **មាស មុត** ទៅជំនុំជម្រះ[13]។

## II. ប្រវត្តិនីតិវិធី

7. សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានពិភាក្សានៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ លើបញ្ហាខ្វែងយោបល់គ្នាទាក់ទងនឹងការប្តឹងចោទជនសង្ស័យថ្មីបន្ថែមទៀត ផ្សេងពីជនសង្ស័យដែលមានស្រាប់នៅ អ.វ.ត.ក ដើម្បីបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតឱ្យបើកការស៊ើបសួរ[14]។ ក្នុងនោះជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺមានបំណងបញ្ជូនជនសង្ស័យបន្ថែម (សំណុំរឿងលេខ០០៣

---

[7] ឯកសារ **D267/1/3** សេចក្តីសម្រេចលើសំណើ **មាស មុត** សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩។

[8] ឯកសារ **D267/2** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩។

[9] វិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[10] វិធាន៦៧(៥) នៃវិធានផ្ទៃក្នុង (ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត) ដែលបានផ្តល់ជូនសហព្រះរាជអាជ្ញានូវការជូនដំណឹងជាបន្ទាន់អំពីដីកាដំណោះស្រាយ និងការបើកផ្លូវប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយនេះ។

[11] វិធាន៧៣(ក) នៃវិធានផ្ទៃក្នុង (យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ) ដែលបានផ្តល់សមត្ថកិច្ចដល់អង្គបុរេជំនុំជម្រះនូវសមត្ថកិច្ចពិនិត្យលើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។

[12] វិធាន៧៤(២) នៃវិធានផ្ទៃក្នុង (មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ) ដែលបានផ្តល់សិទ្ធិជូនសហព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត។

[13] ឯកសារ **D267** ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

[14] សហព្រះរាជអាជ្ញាអន្តរជាតិ បានបើកការស៊ើបអង្កេតបឋមស្ងាត់ៗដោយឯកឯង ដោយមិនបានជូនដំណឹង និងមិនមានការចូលរួមពីសហព្រះរាជអាជ្ញាជាតិឡើយ។ ការណ៍គឺផ្ទុយនឹងច្បាប់ អ.វ.ត.ក ដែលបានតម្រូវឲ្យសហព្រះរាជអាជ្ញាទាំងពីរធ្វើការរួមជាមួយគ្នានៅក្នុងការិយាល័យសហព្រះរាជអាជ្ញា។

និង០០៤) ទៅសហចៅក្រមស៊ើបអង្កេតដើម្បីបើកកិច្ចស៊ើបសួរ។ ចំណែកឯសហព្រះរាជអាជ្ញាជាតិ មានជំហរមិនឯកភាពឲ្យមានជនសង្ស័យបន្ថែម ផ្សេងពីជនសង្ស័យដែលមានស្រាប់នៃសំណុំរឿង លេខ០០១ និង០០២ ឡើយ[15]។

8. ករណីខ្វែងយោបល់គ្នានេះ ត្រូវបានសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានលើកអំណះអំណាង រៀងៗខ្លួន ដើម្បីដាក់ជូនអង្គបុរេជំនុំជម្រះពិនិត្យ និងសម្រេចតាមនីតិវិធីច្បាប់។ ជាលទ្ធផលអង្គបុរេ ជំនុំជម្រះមិនទទួលបាននូវសម្លេងគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ដើម្បីធ្វើសេចក្តីសម្រេចលើការ ខ្វែងយោបល់គ្នានោះទេ។[16]

9. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា នៅពេលដែលអង្គបុរេជំនុំជម្រះ មិនអាចឈានដល់ការធ្វើសេចក្តី សម្រេចលើការខ្វែងយោបល់គ្នាដែលបាននាំយកមកដោះស្រាយនៅចំពោះមុខខ្លួននោះ យោងតាម វិធាន ៧៤.១ នៃវិធានផ្ទៃក្នុង គឺមានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបញ្ជូនដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដើម្បីបើកកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៣.១ នៃវិធានផ្ទៃក្នុង។[17]

10. ដោយអនុលោមតាមសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ លើ ការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ស្របតាមវិធាន៧១ នៃវិធានផ្ទៃក្នុង[18] នៅថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿងលេខ០០៣ និង០០៤ ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ លើសំណុំរឿងទាំងពីរនេះ។[19]

---

15 កំណត់ហេតុ នៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិលើការចោទប្រកាន់ជន សង្ស័យថ្មីបន្ថែម ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

16 ឯកសារលេខ **D1/1.1** និង **D1/1.3** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

17 ឯកសារលេខ **D1/1.1** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ របស់អង្គបុរេជំនុំជម្រះ។

18 ឯកសារ **D1/1.3** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោម តាមវិធាន៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩។

19 ឯកសារ **D1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ ស៊ើបសួរទី២ និងទី៣ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។

11. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង **មាស មុត** និង **ស៊ូ ម៉េត** ដោយជូនដំណឹងភាគីថាមានពេល១៥ថ្ងៃបន្ទាប់ពីសេចក្ដីជូនដំណឹងនេះ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម[20]។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតបានដឹងថា **ស៊ូ ម៉េត** បានទទួលមរណភាព ដែលនីតិវិធីពាក់ព័ន្ធតាមផ្លូវច្បាប់ត្រូវបានដោះស្រាយនៅក្នុងដីកាដំណោះស្រាយ[21]។

12. នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង **មាស មុត** ហើយបានជូនដំណឹងដល់ភាគីថា នឹងមិនអនុញ្ញាតឲ្យមានសំណើសុំបំពេញកិច្ចស៊ើបសួរឡើយ[22]។

13. នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿងមកសហព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ[23]។ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយបានស្នើឲ្យលើកលែងចោទប្រកាន់លើ **មាស មុត** ដោយមូលហេតុថា **មាស មុត** មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ[24]។

## III. សារណា

### ការកកើតកងទ័ពបដិវត្តកម្ពុជា

14. កងទ័ពបដិវត្តកម្ពុជាមានដើមកំណើតចេញពី "កងការពារសម្ងាត់"។[25] នៅឆ្នាំ១៩៦៨ កងការពារសម្ងាត់នេះ ត្រូវបានប្រែក្លាយទៅជា "កងឈ្លបប្រដាប់អាវុធ"។[26] នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨

---

[20] ឯកសារ **D13** សេចក្ដីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង **មាស មុត** ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។

[21] ឯកសារ **D256** ដីកាបញ្ជូនរឿងមូលទៅពិនិត្យអនុលោមតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង កថាខណ្ឌទី៣ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។

[22] ឯកសារ **D252** សេចក្ដីជូនដំណឹងលើកទី២ អំពីការបិទការស៊ើបសួរប្រឆាំង **មាស មុត** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧។

[23] ឯកសារ **D256** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។

[24] ឯកសារ **D256/6** ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង របស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧។

[25] ឯកសារ **D4.1.861** ទស្សនាវដ្ដី បក្សកុម្មុយនីស្តកម្ពុជាមានចំណងជើងថា "ទង់បដិវត្ត" លេខ៖ ០៨ ចេញផ្សាយខែសីហា ឆ្នាំ១៩៧៥ ទំព័រ១៩។

[26] ឯកសារ **D4.1.861** ទស្សនាវដ្ដី បក្សកុម្មុយនីស្តកម្ពុជាមានចំណងជើងថា "ទង់បដិវត្ត" លេខ៖ ០៨ ចេញផ្សាយខែសីហា ឆ្នាំ១៩៧៥ ទំព័រ២០។

ជាថ្ងៃនៃការចាប់ផ្តើមធ្វើការតស៊ូប្រដាប់ដោយអាវុធជាផ្លូវការ និងជាថ្ងៃកំណើតកងទ័ពបដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា។[27] ក្រោយមក បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថា ចាប់ពីឆ្នាំ១៩៦៩ មានការចងក្រងលក្ខខណ្ឌសម្រាប់កងទ័ពនៅតាមភូមិភាគសំខាន់ៗខ្លះ ដោយមាកកងអនុសេនាធំជាច្រើនរួចទៅហើយ។ នៅកន្លែងផ្សេងទៀត មានត្រឹមតែអនុសេនាតូច ក្រុម និងពួក។ កម្លាំងទាំងនេះគឺស្ថិតនៅក្នុងជួរកងទ័ពបដិវត្ត។[28] នៅក្នុងខែមីនា ឆ្នាំ១៩៧០ កម្លាំងទាំងនេះត្រូវបានកំណត់ឈ្មោះជាផ្លូវការថា "កម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា"។[29]

15. ការរៀបចំជាផ្លូវការនៃកងកម្លាំងប្រដាប់អាវុធនេះ ត្រូវបានប្រកាសជាសាធារណៈនៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ ក្នុងអង្គប្រជុំមួយដែលគេហៅថា "សន្និសីទនយោបាយសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា" ដែលមានតំណាងមកពីអង្គភាពនានានៃកងទ័ពបដិវត្តប្រហែលចំនួន៣០០០នាក់ចូលរួម និងមានសមមិត្តប្រធានគណៈយោធាកំពូលរបស់បក្ស ដែលបានថ្លែងទៅកាន់អ្នកចូលរួម។[30] ការចាត់តាំងនេះ បានបញ្ចូលកងពលតូចគ្រប់តំបន់ ដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម គឺស្ថិតនៅក្រោមបញ្ជារបស់សេនាធិការដែលមាន សុន សេន ជាអគ្គសេនាធិការ។[31]

## រចនាសម្ព័ន្ធកងទ័ពបដិវត្តកម្ពុជា

16. រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានផ្តល់កងទ័ពបដិវត្តកម្ពុជានូវកាតព្វកិច្ច "ការពារអំណាចរដ្ឋ" និង "ជួយកសាងប្រទេស"[32]។ កងទ័ពបដិវត្តកម្ពុជា មានការទទួលខុសត្រូវទូទៅខាងផ្នែកសន្តិសុខខាងក្រៅ និងផ្នែកខាងក្នុង[33]។ កងទ័ពបដិវត្តកម្ពុជា ត្រូវបានបែងចែកជាបីសាខាគឺ៖ ស្រួច

[27] ឯកសារ **D4.1.861** ទស្សនាវដ្តី បក្សកុម្មុយនីស្តកម្ពុជាមានចំណងជើងថា "ទង់បដិវត្ត" លេខ៖ ០៨ ចេញផ្សាយខែសីហា ឆ្នាំ១៩៧៥ ទំព័រ២០។ ឯកសារ **D4.1.861** ទស្សនាវដ្តី បក្សកុម្មុយនីស្តកម្ពុជាមានចំណងជើងថា "ទង់បដិវត្ត" លេខពិសេស ចេញផ្សាយខែធ្នូ ឆ្នាំ១៩៧៦ ទំព័រ២៣ និងខែមករា ឆ្នាំ១៩៧៧ ទំព័រ២៨។

[28] ឯកសារ **D4.1.861** ទស្សនាវដ្តី បក្សកុម្មុយនីស្តកម្ពុជាមានចំណងជើងថា "ទង់បដិវត្ត" លេខ៖ ០៨ ចេញផ្សាយខែសីហា ឆ្នាំ១៩៧៥ ទំព័រ២៣។

[29] ឯកសារ **D4.1.861** ទស្សនាវដ្តី បក្សកុម្មុយនីស្តកម្ពុជាមានចំណងជើងថា "ទង់បដិវត្ត" លេខ៖ ០៨ ចេញផ្សាយខែសីហា ឆ្នាំ១៩៧៥ ទំព័រ១៩។

[30] ឯកសារ **D4.1.861** ទស្សនាវដ្តី បក្សកុម្មុយនីស្តកម្ពុជាមានចំណងជើងថា "ទង់បដិវត្ត" លេខ៖ ០៨ ចេញផ្សាយខែសីហា ឆ្នាំ១៩៧៥ ទំព័រ១៩។

[31] ឯកសារ **D4.1.855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡុញ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៣។

[32] ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, **D1.3.22.2** ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦, ERN 00089841-00089852 (ភាសាខ្មែរ), ជំពូក១៦។

[33] សូមមើល ទស្សនាវដ្តី បកក ដែលមានចំណងជើងថា ទង់បដិវត្ត, **D1.3.24.2** នៅខែកក្កដា ឆ្នាំ១៩៧៦ ត្រង់ទំព័រ ៧-៩, ERN 00062905-00062945 (ភាសាខ្មែរ) (ដែលរៀបរាប់ពីភាពចាំបាច់ក្នុងការការពារប្រទេស "ផ្ទៃក្នុងប្រទេស" និង "នៅលើឆាកអន្តរ

តំបន់ ឈ្លប[34]។ សាខាទាំងបីនេះ "ស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខដាច់ខាត" របស់បក្សកុម្មុយនីស្ត កម្ពុជា[35]។

17. កងទ័ពបដិវត្តកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈយោធា ដែលជាគណៈកម្មាធិការក្រោមចំណុះគណៈមជ្ឈិម[36] របស់បក្សកុម្មុយនីស្តកម្ពុជា ដែលទទួលខុសត្រូវផ្នែកយោធា និងសន្តិ

ជាតិ"; ទស្សនាវដ្តី បកក ដែលមានចំណងជើងថា យុវជនបដិវត្ត, **D1.3.24.1** នៅខែឧសភា ឆ្នាំ១៩៧៦ ត្រង់ទំព័រ ៤-៥, ERN 00064003-00064040 (ភាសាខ្មែរ)-(ដែលនិយាយថា កងទ័ព"ត្រូវលើកកំពស់ ជានិច្ចនូវស្មារតីបដិវត្តខ្លាំងក្លារបស់ខ្លួន និងត្រូវត្រៀមខ្លួនជាស្រេចឱ្យរឹងមាំបំផុត និងល្អឥតខ្ចោះក្នុងការ ការពារព្រំដែនទឹក ដី សមុទ្រ កោះ និងនៅក្នុងប្រទេសដើម្បីធានាសន្តិសុខរបស់ ប្រជាជនយើងនៅក្នុង សហករណ៍") ។ ទស្សនាវដ្តី បកក ដែលមានចំណងជើងថា *ទង់បដិវត្ត*, **D1.3.6.1** ខែមិថុនា ឆ្នាំ ១៩៧៦, ត្រង់ទំព័រ ៨-៩, ERN 00062836-00062876 (ភាសាខ្មែរ)។

[34] ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, ជំពូក ១៦, **D1.3.22.2** ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦ ERN 00089841-00089852 (ភាសាខ្មែរ); សូមមើលផងដែរ ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា លក្ខន្តិកៈបក្សកុម្មុនិស្តកម្ពុជា, **D1.3.22.1** ខែមករា ឆ្នាំ១៩៧៦, ERN 00053007-00053080, មាត្រា ២៧ (ដែលនិយាយ យោងដល់សាខាទាំងបីដូចគ្នាថា ស្រួច តំបន់ និង ឈ្លប)។

[35] ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា លក្ខន្តិកៈបក្សកុម្មុនិស្តកម្ពុជា, **D1.3.22.1** ខែមករា ឆ្នាំ១៩៧៦, ត្រង់ទំព័រ ២៥, ERN 00053007-00053080; កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា, **D1.3.27.1** ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥, ត្រង់ទំព័រ ២, ERN 00019108-00019126 (ភាសាខ្មែរ) (ក្នុងនោះ គណៈអចិន្ត្រៃយ៍បានកត់សម្គាល់នៅក្នុងកំណត់ហេតុប្រជុំរបស់ខ្លួនថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ថា "កិច្ចការការពារជាតិត្រូវរៀបចំនៅថ្នាក់មជ្ឈិម") ។ ទស្សនាវដ្តី បកក ដែលមានចំណងជើងថា ទង់បដិវត្ត, **D1.3.24.2** ខែកក្កដា ឆ្នាំ១៩៧៦, ទំព័រ ៦៥, ERN 00062905-00062945 (ភាសាខ្មែរ) ("មានតែបក្សដែលដឹកនាំកងទ័ព ដោយពុំមានអង្គការ ឬបុគ្គលណាម្នាក់ដឹកនាំកងទ័ពឡើយ"។)

[36] តួនាទីរបស់គណៈមជ្ឈឹមបក្សកុម្មុយនិស្តកម្ពុជា មានបញ្ជាក់នៅក្នុងផ្នែកនៃដីកាបញ្ជូនរឿងឱ្យស៊ើប សួររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា បក្សកុម្មុយនិស្តកម្ពុជា និងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជា និងមន្ទីរ ៨៧០, **D10.1.95**, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, កឋាខ័ណ្ឌ ២២-២៤, ERN 00185898-00186167 (ភាសាអង់គ្លេស)។ សូមមើលផងដែរ ផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថាការពិនិត្យលើឋានុក្រមនៃកម្ពុជាប្រជាធិបតេយ្យ និងគណៈអចិន្ត្រៃយ៍, **D10.1.95**, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, កឋាខ័ណ្ឌ៦ និង១១-១៣, ERN 00185898-00186167 (ភាសាអង់គ្លេស)។

សុខ[37]។ គណៈយោធា មានសមាជិកគណៈអចិន្ត្រៃយ៍[38] ប៉ុល ពត[39], នួន ជា និង សុន សេន[40] (ហៅ ខៀវ ឬ បង៨៩) ក៏ដូចជាកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា[41]។

## អគ្គសេនាធិការ

18. អគ្គសេនាធិការរបស់កងទ័ពបដិវត្តកម្ពុជាដើរតួជាទីបញ្ជាការកណ្តាលរបស់កងទ័ព ហើយបំពេញមុខងារ ជាច្រើនដូចជា រៀបចំគម្រោង ធ្វើបេសកកម្ម ស៊ើបការណ៍សម្ងាត់ និងភស្តុភារ។ សុន សេន មានតំណែងជាប្រធានអគ្គសេនាធិការ[42]។ សុន សេន ត្រូវបានជួយក្នុងការងារដោយកម្មាភិបា

---

[37] សំដីរបស់ អៀង សារី ហៅ វ៉ាន់, **D1.3.33.2** ថ្ងៃទី ៦ ដល់ ១៩ ខែកញ្ញា ឆ្នាំ១៩៩៦, ត្រង់ទំព័រ ៦, ERN 00078605-00078618 (ភាសាអង់គ្លេស) ("គឺមានគណៈកម្មាធិការ ដែលពិនិត្យលើរាល់បញ្ហាអំពីសន្តិសុខ")។

[38] តួនាទីរបស់គណៈមជ្ឈឹមបក្សកុម្មុយនិស្តកម្ពុជា មានបញ្ជាក់នៅក្នុងផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា បក្សកុម្មុយនិស្តកម្ពុជា និងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជា និងមន្ទីរ ៨៧០, **D10.1.95**, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២00៧, កថាខណ្ឌ ២៤-២៨, ERN 00185898-00186167 (ភាសាអង់គ្លេស)។ សូមមើលផងដែរផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា ការពិនិត្យលើឋានុក្រមនៃកម្ពុជាប្រជាធិបតេយ្យ និងគណៈអចិន្ត្រៃយ៍, **D10.1.95**, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២00៧, កថាខណ្ឌ៦ និង១១-១៣, ERN 00185898-00186167 (ភាសាអង់គ្លេស)។

[39] នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ របស់គណៈអចិន្ត្រៃយ៍, ប៉ុល ពត ត្រូវបានប្រគល់ការទទួលខុសត្រូវទូទៅលើកងទ័ព។ កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃ បកក, **D1.3.27.1** ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥, ត្រង់ទំព័រ ១, ERN 00019108-00019126 (ភាសាខ្មែរ)។

[40] ក្នុងខែមិនា ឆ្នាំ១៩៧៦, សុន សេន ត្រូវបានតែងតាំងជា ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុក ការពារជាតិ។ សារាចរណែនាំរបស់គណៈមជ្ឈឹមបក្សកុម្មុយនិស្តកម្ពុជា ដែលមានចំណងជើងថា សេចក្តីសម្រេចរបស់គណៈមជ្ឈឹមទាក់ទងនឹងបញ្ហាមួយចំនួន, **D1.3.19.1**, ថ្ងៃទី៣0 ខែមីនា ឆ្នាំ១៩៧៦, ERN 00003136-00003142 (ភាសាខ្មែរ)។ សូមមើលផងដែរ កំណត់ហេតុប្រជុំរបស់សភាប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ឯកសារស្តីអំពីសម័យប្រជុំលើកទី១ នីតិកាលទី១របស់សភាតំណាងប្រជាជនកម្ពុជា, ថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦, **D1.3.27.4**, ត្រង់ទំព័រ ៤៨-៤៩, ERN 00053603-00053645 (ភាសាខ្មែរ)។ សុន សេន ក៏ជាសមាជិកនៃគណៈមជ្ឈឹមបក្សកុម្មុយនិស្តកម្ពុជាដែរ ។ សំដីរបស់ **ខៀវ សំផន** ស្រង់ដោយ កសចស , **D1.3.33.15**, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២00៧, ត្រង់ទំព័រ ១0, ERN 00156741-00156751 (ភាសាខ្មែរ)។

[41] សំដីរបស់ **អៀង សារី ហៅ វ៉ាន់**, **D1.3.33.2** ថ្ងៃទី៦ ដល់ ១៩ ខែកញ្ញា ឆ្នាំ១៩៩៦, ត្រង់ទំព័រ ៦, ERN 00078605-00078618 (ភាសាអង់គ្លេស) (អៀង សារី និយាយថា គឺគណៈកម្មាធិការដែលដោះស្រាយរាល់បញ្ហាសន្តិសុខ "ដែលមានមនុស្ស៤នាក់: ប៉ុល ពត, នួន ជា, សុន សេន និង ទីប្រឹក្សា សុន សេន ឈ្មោះ យុន យ៉ាត")។

[42] កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃ បកក, **D1.3.27.1** ថ្ងៃទី ៩ ខែតុលា ឆ្នាំ១៩៧៥, ត្រង់ទំព័រ ១, ERN 00019108-00019126 (ភាសាខ្មែរ) (ដែលផ្តល់ឱ្យ សុន សេន នូវការទទួលខុសត្រូវលើអគ្គសេនាធិការ និងសន្តិសុខ), កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ, **D1.3.19.2** ដែលមានចំណងជើងថា ជូនគណៈកម្មាធិការកងពល និងវរសេនាធំ, ERN 00033314-00033314 (ភាសាខ្មែរ) (ដែលនៅក្នុងនោះ សុន សេន ចេញការណែនាំពីអគ្គសេនាធិការទៅ កងពល និង វរសេនាធំ); សំដីរបស់ **កាំង ហ្គេច អ៊ាវ** ហៅ **ឌុច** ស្រង់ដោយ កសចស, **D1.3.33.3** ថ្ងៃទី៧ ខែសីហា ឆ្នាំ២00៧, ERN 00147518, ERN 00147517-00147527 (ភាសាអង់គ្លេស)។

ល បក្សកុម្មុយនីស្តកម្ពុជាដែលបានបញ្ជូនទៅធ្វើការនៅក្នុងអគ្គសេនាធិការ។ ក្នុងនោះមាន រ៉ែន[43] និង ទាញ[44]។ ជារួម អគ្គសេនាធិការ និងមន្ទីរក្រោមចំណុះនានា មន្ទីរ៦២ និងមន្ទីរ៦៣ មានបុគ្គលិក ចំនួន ៤,៥០០ នាក់[45]។

19. តួនាទីសំខាន់មួយរបស់អគ្គសេនាធិការ គឺរក្សាសន្តិសុខផ្ទៃក្នុង ដែលរាប់បញ្ចូលទាំងការឃ្លាំមើល "ខ្មាំងផ្ទៃក្នុង" និងចាត់វិធានការកម្ទេចខ្មាំង[46]។ ពិសេសគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា

---

[43] កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សេចក្តីរាយការណ៍ ពីស្ថានភាពនៅកងពល ៣១០ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦, **D1.3.12.15,** ERN 00160067-00160067 (ភាសាខ្មែរ) (សេចក្តីរាយការណ៍របស់មន្ទីរអគ្គសេនាធិការដែលចុះ ហត្ថលេខា ដោយឈ្មោះ រ៉ែន); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សេចក្តីរាយការណ៍ពីស្ថានភាពនៅ កងពល៤៥០ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.9.2,** ERN 00052338-00052340 (ភាសាខ្មែរ) (សេចក្តីរាយការណ៍របស់មន្ទីរ អគ្គសេនាធិការដែលចុះហត្ថលេខា ដោយឈ្មោះ រ៉ែន)។ កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ការប្រជុំ នៅកន្លែងរបស់កងពល ១៧០ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦, **D1.3.8.6,** ERN 00160137-00160141 (ភាសាខ្មែរ) (កំណត់ហេតុប្រជុំអគ្គសេនាធិការជាមួយកងពល១៧០ចុះហត្ថលេខាដោយឈ្មោះ រ៉ែន)។

[44] របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧, **D1.3.9.4,** ERN 00052314-00052314 (ភាសាខ្មែរ) (ឯកសារពីគណៈកម្មាធិការភ័ស្តុភារសេនា ធិការ ជូនចំពោះ បង ៨៩ និង បង ៨១ ចុះហត្ថលេខាដោយឈ្មោះ ទាញ); របាយការណ៍ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ស្ថិតិអាវុធ និងគ្រាប់រំសេវដែលស្នើដោយ កងពល ៤៥០ និង ៥០២ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦, **D1.3.12.5,** ERN 00160097-00160097 (ភាសាខ្មែរ) (ឯកសារអគ្គសេនាធិការដែលចុះហត្ថលេខាដោយឈ្មោះ ទាញ); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ផែនការប្រើប្រាស់អង្ករ សម្រាប់ឆ្នាំ១៩៧៦ ដោយអង្គភាព ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦, **D114/27.1.7** ERN 00160081-00160081 (ភាសាខ្មែរ) (របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យដែល ចុះហត្ថលេខា ដោយឈ្មោះ ទាញ)។

[45] អគ្គសេនាធិការមានមន្ទីរក្រោមចំណុះ២ទៀត៖ មន្ទីរ ៦២ និងមន្ទីរ ៦៣។ មន្ទីរ ៦២ មាន ការិយាល័យក្រោមចំណុះចំនួនទៀត: ក-១៥, ក-១៦, ក-១៨, ក-២៧, ក-២៨, ៣៩៨, វ-៦៦, ត្រាកទ័រ និងឡានទឹក។ មន្ទីរ ៦២ មានបុគ្គលិក ១.៣៨៥ នាក់, ចំណែកឯមន្ទីរ ៦៣ មានបុគ្គលិក ៣.២០១ នាក់។ របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើង ថា របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យស្តីពីស្ថិតិកម្លាំងកងទ័ពទូទៅ, **D54/47.1,** ERN 00052319-00052319 (ភាសាខ្មែរ) ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧។ ឯកសារមួយផ្សេងទៀតនិយាយយោងដល់មន្ទីរជាច្រើននៅក្នុងអគ្គសេនាធិការ រួមមាន "ភស្តុភារកង ទ័ព", "អង្គភាពរថក្រោះ", "អង្គភាពកាំភ្លើងធំ" និង "មន្ទីរសេនាធិការ"។ ទាំងនេះអាចថាជាឈ្មោះ ផ្សេងទៀតរបស់មន្ទីរ ៦២ និង ៦៣ និងមន្ទីរក្រោមចំណុះជាច្រើន"។ របាយការណ៍កងទ័ព កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ផែនការប្រើប្រាស់អង្ករសម្រាប់ឆ្នាំ១៩៧៦ ដោយអង្គភាព ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦, **D114/27.1.7** ERN 00160081-00160081 (ភាសាខ្មែរ)។

[46] កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំដកពិសោធន៍លើការយាមកាម ការពារទីក្រុង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.8.9,** ERN 00162477-00162479 (ភាសាខ្មែរ) (កំណត់ហេតុប្រជុំអគ្គសេនាធិការរៀបរាប់ពី ស្ថានភាពខ្មាំងបង្កប់នៅក្នុងប្រទេស និងនៅតាមព្រំដែន); កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណង ជើងថា សេចក្តីសង្ខេបពីស្ថានភាពខាងក្នុងប្រទេស និងនៅតាមព្រំដែន យោងតាមទូរលេខពី ១ ដល់ ៣១ ខែធ្នូ ឆ្នាំ១៩៧៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.12.16,** ERN 00160073-00160077 (ភាសាខ្មែរ) (ឯកសារអគ្គសេនាធិការផ្តល់នូវសេចក្តីសង្ខេបពីសកម្មភាពដែលកើតឡើងនៅ ក្នុងប្រទេស និងនៅតាមព្រំដែន); កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែល

ផ្ដល់អំណាច ឱ្យអគ្គសេនាធិការជាអ្នកកំណត់ថាតើបុគ្គលិកកងទ័ពបដិវត្តកម្ពុជាណាខ្លះ ដែលត្រូវយកទៅសម្លាប់ ដើម្បីបម្រើនយោបាយបក្សកុម្មុយនីស្តកម្ពុជា[47]។ អគ្គសេនាធិការបានប្រើប្រាស់អំណាចនេះ ហើយកម្មាភិបាល អគ្គសេនាធិការជាច្រើន ត្រូវបានបញ្ជូនទៅមន្ទីរស-២១[48] ដែលនៅទីនោះពួកគេត្រូវបានសម្លាប់ចោល[49]។

---

មានចំណង ជើងថាប្រជុំនៅកន្លែងកងពល១៧0 ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦, **D1.3.8.6,** ERN 00160137-00160141 (ភាសាខ្មែរ) (រៀបរាប់ពី "ចំពោះមុខ"ក្នុងការការពារប្រទេស ហើយនិយាយថា សមមិត្តណាដែលមាន "និន្នាការនយោបាយមិនល្អ" ត្រូវតែដកចេញ ដើម្បីការពារសន្តិសុខផ្ទៃក្នុង)។

[47] សារាចរណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ដែលមានចំណងជើងថា សេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗ, **D1.3.19.1** ថ្ងៃទី៣0 ខែមីនា ឆ្នាំ១៩៧៦, ERN 00003136-00003142 (ផ្ដល់សិទ្ធិឱ្យអគ្គសេនាធិការ "កម្ទេច" បុគ្គលនៅក្នុង "កងទ័ពមជ្ឈិម")។

[48] ស-២១ គឺជាមន្ទីរសន្តិសុខសំខាន់របស់ បកក នៅក្នុងក្រុងភ្នំពេញ។ មានការរៀបរាប់ពីមន្ទីរ នេះយ៉ាងលម្អិតបន្ថែមទៀតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ដែល មានចំណងជើងថា ភ្នំពេញ-មន្ទីរស-២១, **D10.1.95,** ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២00៧, កថាខ័ណ្ឌ ៤៩-៥៥, ERN 00185898-00186167 (ភាសាអង់គ្លេស)។

[49] សូមមើល, ឧទាហរណ៍, បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះរបស់អ្នកទោសមកពី មន្ទីរអគ្គសេនាធិការ, ពេទ្យកងទ័ព និងអង្គភាពផ្សេងៗទៀត, **D1.3.28.18,** ឆ្នាំ១៩៧៧, ERN 00021118-00021120 (បញ្ជីឈ្មោះ៣៧នាក់ដែលត្រូវបានចាប់ខ្លួន, ១៣នាក់មកពី អគ្គសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះរបស់អ្នកទោសមកពីអគ្គសេនាធិការ ឆ្នាំ១៩៧៧, **D1.3.28.26,** ERN 00021222-00021229 (ភាសាខ្មែរ) (ចុះបញ្ជីឈ្មោះមនុស្ស ៧៦នាក់ មកពីមន្ទីរអគ្គសេនាធិការ, ៤នាក់បានបញ្ជាក់ថា "កម្ទេច")។ បញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា របាយការណ៍របស់ ចាន់ អំពីអ្នកទោស១៣នាក់បញ្ជូនមក ស-២១ ថ្ងៃ២១ ឧសភា ១៩៧៧, **D1.3.28.31,** ERN 00088738-00088739 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោសមួយចំនួនមកពីភស្ដុភារសេនាធិការ)។ បញ្ជីអ្នកទោស ស-២១ ដែលមាន ចំណងជើងថា របាយការណ៍របស់ ចាន់ អំពីអ្នកទោស ១៨នាក់បញ្ជូនមក ស-២១ ថ្ងៃ២២ ឧសភា ១៩៧៧, **D1.3.28.32,** ERN 00088736-00088737 (ភាសាខ្មែរ) (មានឈ្មោះអ្នក ទោសមួយចំនួនមកពីសេនាធិការ)។ បញ្ជីអ្នកទោស ស-២១, **D1.3.28.34** ថ្ងៃ២៨ ឧសភា ១៩៧៧ ERN 00072579-00072581 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៣0នាក់ ក្នុងនោះមានទាំងអ្នកទោសមកពីអគ្គសេនាធិការដែរ); បញ្ជីអ្នកទោស ស-២១, **D1.3.28.37** ខែធ្នូ ១៩៧៧, ERN 00040237-00040237 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៨នាក់); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសមកពីសេនាធិការ និងស-២១, **D1.3.28.50** ខែតុលា ១៩៧៧, ERN 00021100-00021102 (ភាសាខ្មែរ) (មានបញ្ជីឈ្មោះមនុស្ស ៥៥នាក់មកពីសេនាធិការ និង ស-២១)។ បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសមកពីមន្ទីរអគ្គសេនាធិការ, **D1.3.28.59,** ខែមករា ១៩៧៨, ERN 00021090-00021091 (ភាសាខ្មែរ) (មានឈ្មោះមនុស្ស ៦៦នាក់មកពីសេនា ធិការ ដែលក្នុងនោះ ២៣នាក់ត្រូវបានបញ្ជាក់ថា បានចាប់ខ្លួនរួចហើយ); បញ្ជីអ្នកទោស ស-២១, **D1.3.28.60,** ថ្ងៃ១៨ មករា ១៩៧៨, ERN 00021241-00021243 (ភាសាខ្មែរ) (បញ្ជីឈ្មោះ ១៣នាក់ ដែល៥នាក់មកពីមន្ទីរសេនាធិការ)។ បញ្ជីអ្នកទោស ស-២១, **D1.3.28.102** ខែឧសភា ១៩៧៨, ERN 00019233-00019249 (មានឈ្មោះអ្នក ទោស ២៧0នាក់ ដែលខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោស មកពីមន្ទីរចំណុះសេនាធិការ, ខែកក្កដា ១៩៧៨, **D1.3.28.64,** ERN 00021092-00021093 (មានឈ្មោះមនុស្ស ២២នាក់ដែលចាប់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ថ្ងៃ៣0 មីនា ១៩៧៨, **D1.3.28.65,** ERN 00086721-00086724 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៨៤នាក់ ដែលអ្នកទោសខ្លះមកពីសេនាធិការ; បញ្ជីអ្នកទោស ស-២១, ថ្ងៃទី២ មេសា ១៩៧៨, **D1.3.28.66,** ERN 00088616-00088630 (ភាសាខ្មែរ) (ដែលមានឈ្មោះអ្នក

ទោស ១៤៤នាក់, ខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.67** ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៨, ERN 00088602-00088611 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៨៨នាក់ ដែលអ្នកទោសខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D1.3.28.75** ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨, ERN 00086873-00086873 (ភាសាខ្មែរ) (រួមមានអ្នកទោសមកពីសេនា ធិការ)។ បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមឯកសារ", **D1.3.28.74** ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨, ERN 00086894-00086898 (ភាសាខ្មែរ) បញ្ជីអ្នកទោស ៧៦នាក់ដែលមានអ្នកខ្លះមក ពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.84** ថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៨, ERN 00088586-00088593 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៩៩នាក់ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.85** ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៨, ERN 00088568-00088585 (ភាសាខ្មែរ) (បញ្ជីអ្នក ទោស ១១០នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.86** ថ្ងៃ ទី២៥ ខែមេសា ឆ្នាំ១៩៧៨, ERN 00039788-00039811 (ភាសាខ្មែរ) (មាន ឈ្មោះអ្នកទោស ៣០៧នាក់ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមាន ឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D1.3.28.87** ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៨, ERN 00086874-00086874 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន ១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D1.3.28.95** ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨, ERN 00086872-00086872 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន ១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D1.3.28.104** ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៨, ERN 00086875-00086875 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D1.3.28.106** ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៨, ERN 00086876-00086876 (ភាសខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន ១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោស សួរចម្លើយថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៨, **D1.3.28.105,** ERN 00088656-00088662 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៨៩នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.111,** ERN 00040144-00040146 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ២៧នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមាន ឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមក្តៅ", **D1.3.28.125** ខែមិថុនា ឆ្នាំ១៩៧៨, ERN 00086865-00086867 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៣៤នាក់ ដែលអ្នកខ្លះមកពីអង្គភាពរថក្រោះសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.129** ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៨, ERN 00040015-00040016 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ១៨នាក់ ដែលអ្នកខ្លះមកពីអង្គភាពរថក្រោះសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.137** ខែធ្នូ ១៩៧៨, ERN 00086822-00086823 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ២២នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសឃុំនៅក្នុងគុក ពិសេស, **D1.3.28.138** ខែធ្នូ ១៩៧៨, ERN 00088520-00088521 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.141** ខែធ្នូ ១៩៧៨, ERN 00086763-00086768 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៦០នាក់ ដែលអ្នកខ្លះមកពីមន្ទីរសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D1.3.28.146** ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨, ERN 00086824-00086836 (ភាសាខ្មែរ) (បញ្ជីអ្នកទោស៤៦នាក់ ដែលអ្នកខ្លះមកពីសេនាធិការ)។

នៅពេលដែលបញ្ជីអ្នកទោសមួយចំនួន ចង្អុលបង្ហាញយ៉ាងច្បាស់ថា អ្នកទោសត្រូវបានសម្លាប់, **កាំង ហ្គេកអ៊ាវ ហៅ ឌុច** ដែលជាប្រធានគុក ស-២១ អស់រយៈពេលស្ទើរតែពេញមួយរបបនៃកម្ពុជាប្រជាធិបតេយ្យ, បានបញ្ជាក់ថា នៅទីបំផុត អ្នកដែលបានចូលមកដល់ ស-២១ ត្រូវបានសម្លាប់។ សំដីរបស់ **កាំង ហ្គេកអ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ កសចស, **D1.3.33.3** ថ្ងៃទី៧ ខែ សីហា ឆ្នាំ២០០៧ តាម ERN 00147524, ERN 00147517-00147527 (ភាសាអង់គ្លេស) (ឌុច និយាយដល់ការសម្លាប់នៅ ស-២១ ជាលក្ខណៈប្រព័ន្ធ ហើយនិយាយថា: "សម្រាប់ជនដែលត្រូវបានបញ្ជូនទៅ ស-២១ គឺត្រូវបានសម្រេចរួចជាស្រេចឱ្យកម្ទេចទាំងអស់... ពុំមានសិទ្ធិដោះលែងឡើយនៅ ស-២១); សំដីរបស់ **កាំង ហ្គេកអ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ កសចស,

20. ក្នុងការប្រើប្រាស់អំណាចកម្ទេចបុគ្គលិកកងទ័ពបដិវត្តកម្ពុជា ពេលខ្លះអគ្គសេនាធិការបានបញ្ជូន កម្មាភិបាលខ្លះទៅតាមមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាសន្តិសុខផ្ទៃក្នុងនៅតាមកងរបស់កងទ័ពបដិវត្តកម្ពុជា[50]។ ប៉ុន្តែតាមការសង្កេតបានឱ្យដឹងថា សិទ្ធិកម្ទេច តែងតាំង ត្រូវបានប្រគល់ទៅឱ្យ

---

**D1.3.33.5** ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ តាម ERN 00147582, ERN 00147579-00147585 (ភាសាអង់គ្លេស) (ឌុច រៀបរាប់ពីរបៀបដែល នួន ជា ប្រាប់ទៅគាត់ថា "គ្រប់អ្នកដែលត្រូវបានបញ្ជូនទៅ ស-២១ ត្រូវតែសម្លាប់ចោល-ដូចដែលខ្ញុំជាអ្នកគ្រប់គ្រង ស-២១, ខ្ញុំអនុវត្តតាមបញ្ជារបស់គាត់"។); **សំដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ កសចស, **D1.3.33.11** ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ តាម ERN 00147565, ERN 00147563-00147573 (ភាសាអង់គ្លេស) (ឌុច រៀបរាប់ពីការទទួល "បញ្ជាដាច់ខាត" នៅថ្ងៃទី២ ឬ ៣ ខែមករា ឆ្នាំ១៩៧៩ ពី នួន ជា ឱ្យ "កម្ទេច" អ្នកទោសនៅ ស-២១ទាំងអស់); សំដីរបស់ **កាំង ហ្គេកអ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ កសចស, **D1.3.33.8** ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ តាម ERN 00149911, ERN 00149907-00149919 (ភាសាអង់គ្លេស) (ឌុច និយាយថា: "អ្នកទោសដែលជាប់ឃុំឃាំងទាំងអស់ត្រូវ តែកម្ទេចចោល។ នៅពេលដំបូង ការសម្លាប់ធ្វើឡើងនៅភ្នំពេញ, ខាងលិច ស-២១។ ក្រោយមក ដោយសារតែខ្លាចមានជម្ងឺឆ្លង ការសម្លាប់ត្រូវធ្វើឡើងនៅជើងឯកវិញ")។

អ្នកផ្សេងទៀតដែលធ្លាប់ធ្វើការនៅ ស-២១ ក៏បានគូសបញ្ជាក់ផងដែរថា អ្នកទោសទាំងអស់ នៅ ស-២១ ត្រូវបានសម្លាប់។ សំដីរបស់ **ប្រ៊ូ ម៉េង** ដែលស្រង់ដោយសហព្រះរាជអាជ្ញា, **D1.3.32.4** ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦, ERN 00080529-00080539 (ភាសាខ្មែរ) (សាក្សីបញ្ជាក់ថា ក្នុងករណីខ្លះ អ្នកជាប់ឃុំត្រូវបានសម្លាប់នៅ ស-២១); សំដីរបស់ **គង់ ផៃ** ដែលស្រង់ដោយសហព្រះរាជអាជ្ញា, **D1.3.32.24** ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៦, ERN 00078666-00078675 (ភាសាខ្មែរ)។ សំដីរបស់ សុខ សុផាត ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារ កម្ពុជា, **D1.3.32.45** ថ្ងៃទី២២ ខែមករា ឆ្នាំ២០០២, ERN 00008163-00008248 (ភាសាខ្មែរ); សំដីរបស់ សោម ម៉ុន ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, **D1.3.32.41** ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៣, ERN 00053936-00053961 (ភាសាខ្មែរ)។ សំដីរបស់ **ហាម សេង** ហៅ **អ៊ុក ប៊ុនសេង** ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, **D1.3.32.13** ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៣, ERN 00008904-00008904 (ភាសាខ្មែរ) (រៀបរាប់ពីរបៀបបញ្ជូនមនុស្សទៅ ស-២១ ហើយពុំដែលឃើញត្រឡប់មកវិញទៅ ហើយហៅ ស-២១ ថាជាកន្លែងសម្លាប់)។ សំដីរបស់ **សោម ម៉េត** ដែលស្រង់ដោយមជ្ឈមណ្ឌល ឯកសារកម្ពុជា, **D1.3.32.40** ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៣, ERN 00051644-00051751 (ភាសាខ្មែរ) (ម៉េត និយាយថា អ្នកទោសត្រូវសម្លាប់ បន្ទាប់ពីសួរចម្លើយរួច)។

[50] សមមិត្ត រ៉េន នៅសេនាធិការ ត្រូវបានបញ្ជូនទៅកងពលជាច្រើន ដើម្បីចុះទៅធ្វើការ ព្រមទាំងជួយដល់កងទ័ពបដិវត្តកម្ពុជា ក្នុងការចាប់ចង និងបោសសម្អាត។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ការប្រជុំនៅកន្លែងកងពល ១៧០, ថ្ងៃ១ តុលា ១៩៧៦, **D1.3.8.6,** ERN 00160137-00160141 (ភាសាខ្មែរ) (សមមិត្ត រ៉េន និយាយថា "វាអាចអនុវត្តវិន័យរបស់បក្ស និងអាចដើរតាមការសម្រេចរបស់បក្ស ដូចជា ដកសមមិត្តណាដែល មាននិន្នាការនយោបាយមិនល្អ។ សមមិត្ត គាត ក៏និយាយដោយដល់សារៈសំខាន់នៃការបោសសម្អាត "សមាសភាពដែលបង្កឱ្យមានគ្រោះថ្នាក់")។ កំណត់ហេតុប្រជុំរបស់ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា របាយការណ៍អំពីស្ថានភាពនៅកងពល ៤៥០ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦, **D1.3.9.2,** ERN 00052338-00052340 (ភាសាខ្មែរ) (រៀបរាប់ពីរបៀបដែលឈ្មោះ រ៉េន ពីមន្ទីរសេនាធិការទៅកងពល ៤៥០ ដើម្បីស៊ើបរកខ្សែក្បត់របស់ ឆើត។ រួមបញ្ចូលឈ្មោះ មនុស្ស ២៥នាក់ មកពីកងពល ៤៥០, កងពល ៣១០, ខាងរោងចក្រ និងខាងពាណិជ្ជកម្ម ដែលមានចង្អុលបង្ហាញឈ្មោះនៅក្នុងចម្លើយសារភាពរបស់ ឆើត)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា របាយការណ៍អំពីស្ថានភាពនៅកងពល ៣១០ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦, **D1.3.12.15,** ERN 00160067-00160067 (ភាសាខ្មែរ) (ពិភាក្សាពី មនុស្ស២នាក់ នៅក្នុងកងពល ៣១០ដែលមានចង្អុលបង្ហាញ

កងពលរបស់កងទ័ពបដិវត្តកម្ពុជា ពិសេស ក្រោយពីបានពិគ្រោះយោបល់ជាមួយមន្ទីរស-២១ ហើយកម្មាភិបាលខ្លះទៀត ត្រូវបានបញ្ជូនទៅអប់រំ[51]។

21. អគ្គសេនាធិការជាអ្នកធ្វើរបាយការណ៍ស្តីអំពីសន្តិសុខខាងក្នុង និងខាងក្រៅ[52] ហើយមានអំណាចដាក់បញ្ហាទាក់ទងទៅនឹងសន្តិសុខខាងក្នុង រួមទាំងបញ្ហាទាក់ទងទៅនឹងឯកសណ្ឋានរបស់កម្មាភិបាល ការយាមកាម ការតាមដាន និងលិខិតអនុញ្ញាតឱ្យកាន់អាវុធ[53]។ វាហាក់ដូចជាថា អគ្គសេនាធិការមានមន្ទីរសន្តិសុខផ្ទាល់ខ្លួន[54]។

---

នៅក្នុងចម្លើយសារភាព។ រ៉ែន និយាយ ថា មនុស្សទាំងពីរនាក់នេះ "ចាប់រួចហើយ" ដោយកងពល); របាយការណ៍របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា របាយការណ៍អំពីស្ថានភាពនៅកងពល ៤៥០ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.9.2**, ERN 00052338-00052340 (ភាសាខ្មែរ) (រ៉ែន រាយការណ៍ត្រឡប់ទៅសេនាធិការអំពី សមមិត្ត ឡុម ហើយស្នើ "ដក"គាត់ចេញពីកងពល ៤៥០)។

[51] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ការប្រជុំ នៅកន្លែងកងពល១៧០ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦, **D1.3.8.6**, ERN 00160137-00160141 (ភាសាខ្មែរ) (កត់សំគាល់ថា មនុស្សជាច្រើនបានបញ្ជូនទៅ "រៀនសូត្រ" ដោយកងពល)។ របាយ ការណ៍របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា គណៈភស្តុភារសេនាធិការគោរពជូនបង ៨៩ និង ៨១, ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧, **D1.3.9.4**, ERN 00052314-00052314 (ភាសាខ្មែរ) (បញ្ជីឈ្មោះពួកជាប់ "ខ្សែក្បត់" នៅភស្តុភារសេនាធិការ។ ចង្អុលបង្ហាញថា "វិធានការខាងចាត់តាំង" ត្រូវបានធ្វើឡើងប្រឆាំងនឹងពួកនោះ)។

[52] របាយការណ៍របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សរុបសភាព ការណ៍នៅក្នុងប្រទេស និងព្រំដែនតាមទូរលេខ ពីថ្ងៃ១ ធ្នូ ដល់ ៣១ ធ្នូ ឆ្នាំ១៩៧៦, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.12.16**, ERN 00160073-00160077 (ភាសាខ្មែរ) (ផ្តល់នូវសេចក្តី សង្ខេបពីការចាប់ខ្លួន និង សកម្មភាពខ្មាំងដែលសង្ស័យ); របាយការណ៍របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា គោរពជូនបង, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦, **D1.3.12.11**, ERN 00021527-00021527 (ភាសាខ្មែរ) (រៀបរាប់ពីពិសោធន៍ល្បាតនៅភ្នំពេញ ដែលកម្មករខ្លះប្រើភ្លើងឆក់ត្រី; រោងចក្រជាច្រើនប្រើប្រាស់កាំភ្លើង និងបើកបរលឿននៅក្នុងក្រុងគឺ ជាសញ្ញា គួរឱ្យព្រួយបារម្ភណ៍); កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើង ថា មន្ទីរ៦២ របស់សេនាធិការ ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៦, **D1.3.12.13**, ERN 00087053-00087053 (ភាសាខ្មែរ) (រាយការណ៍ពីការបាញ់ខ្មាំងដែលចោទថា មានគ្រាប់បែក); កំណត់ ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំដក ពិសោធន៍អំពីការ យាមកាមនៅក្នុងការការពារក្រុង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.8.9**, ERN 00162477-00162479 (ភាសាខ្មែរ) (កំណត់ហេតុប្រជុំសេនាធិការដែលសរុបសភាពការណ៍ខ្មាំង ក្នុងប្រទេស)។

[53] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំដកពិសោធន៍ អំពីការយាមកាមនៅក្នុងការការពារក្រុង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.8.9**, ERN 00162477-00162479 (ភាសាខ្មែរ) (មន្ទីរសេនាធិការចេញបទបញ្ជាពីរឿងយាមកាម និងល្បាត, ការកាន់អាវុធ, ការទទួលបានការរាយការណ៍ពីសភាពការណ៍ខ្មាំងពីគណៈកងពល និងគណៈវរៈឯករាជ, ព្រមទាំងវត្តមានសមមិត្ត)។

[54] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា មន្ទីរ៦២ របស់សេនាធិការ ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៦, **D1.3.12.13**, ERN 00087053-00087053 (ភាសាខ្មែ) (ឯកសារសេនាធិការដែលរាយការណ៍អំពីការបាញ់ជនម្នាក់ដែលសង្ស័យថាជាខ្មាំងដែលគេបានគិតថាមានគ្រាប់បែក)។

22. អគ្គសេនាធិការសម្របសម្រួលការអនុវត្តផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងកងរបស់កងទ័ពបដិវត្តកម្ពុជា ដែលស្ថិតនៅក្រោមចំណុះរបស់អគ្គសេនាធិការ។ ដើម្បីសម្រេចគោលដៅនេះ អគ្គសេនាធិការទំទាក់ទំនងជាមួយកងពល និងកងវរសេនាធំឯករាជ្យ តាមរយៈការប្រជុំជាប្រចាំរវាងប្រធានអគ្គសេនាធិការ និងកម្មាភិបាលជាន់ខ្ពស់របស់កងពល និងកងវរសេនាធំឯករាជ្យ[55]។ នៅក្នុងអង្គប្រជុំទាំងនេះ មេបញ្ជាការកងពលតែងតែរាយការណ៍អំពីសកម្មភាពនៅក្នុងកងពល ផ្តោតទៅលើស្ថានភាពរបស់សត្រូវខាងក្នុង និងខាងក្រៅ និងវិធានការដែលត្រូវចាប់ ដើម្បីរក្សាសន្តិសុខ។ បន្ទាប់មកប្រធានអគ្គសេនាធិការ សុន សេន សង្ខេបអំពីស្ថានភាពនៅក្នុងប្រទេស និងចេញបញ្ជា។

[55] មានកំណត់ហេតុប្រជុំចំនួន១៤លើករបស់លេខាកងពល និងវរៈឯករាជ ដែលអាចជឿបានថា នៅមានការប្រជុំបែបនេះជាច្រើនលើកទៀត។ មានការប្រជុំ ថ្ងៃ២ សីហា ១៩៧៦, ១២ សីហា ១៩៧៦, ១៨ សីហា ១៩៧៦ និង ៣០ សីហា ១៩៧៦ ដែលស្នើថា ការប្រជុំត្រូវធ្វើឡើងរៀងរាល់សប្តាហ៍។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើង ថា កំណត់ហេតុប្រជុំលេខា និងសេដ្ឋកិច្ចកងពល, **D1.3.27.8** ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៦, ERN 00088910-00088910 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំគណៈកងពលទាំងអស់, **D1.3.8.2** ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦, ERN 00162480-00162484 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខា កងពល, លេខា និងអនុលេខាវរៈសេនាធំ, **D1.3.27.10** ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦, ERN 00052352-00052361 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំគណៈកម្មាធិការជាមួយកងពល និងកងវរឯករាជ្យ, **D114/27.1.4** ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦, ERN 00052362-00052375 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែល មានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខាកងពល និងកងវរឯករាជ្យ, **D1.3.27.12** ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦, ERN 00052376-00052379 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខាកងពល និងកងវរឯករាជ្យ, **D1.3.27.13** ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦, ERN 00064954-00064957 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជា ប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងភស្តុភារកងពល និងកងវរៈឯករាជ, **D114/27.1.5** ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦, ERN 00052389-00052401 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែល មានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខាកងពល និងកងវរឯករាជ្យ, **D1.3.27.20** ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦, ERN 00052402-00052416 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខាកងពល និងកងវរឯករាជ្យ, **D1.3.8.7** ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦, ERN 00095528-00095531 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខាកងពល និងកងវរឯករាជ្យ, **D1.3.27.21** ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦, ERN 00088918-00088920 (ភាសាខ្មែរ); កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំពេញអង្គកងពល, **D1.3.27.21** ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦, ERN 00088918-00088920 (ភាសាខ្មែរ); កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងភស្តុភារកងពល និងកងវរឯករាជ្យ, **D1.3.27.23** ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦, ERN 00095507-00095527 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខាកងពល និងកងវរឯករាជ្យ, **D1.3.27.26** ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧, ERN 00052304-00052311 (ភាសា ខ្មែរ)។

23. អគ្គសេនាធិការ និងមេបញ្ជាការកងពលនីមួយៗក៏បានប្រជុំដែរ[56]។ ការប្រជុំខ្លះបានធ្វើឡើងស្រប ពេលជាមួយការប្រជុំរវាងមេបញ្ជាការកងពល និងកងវរសេនាធំទាំងអស់[57]។ លើសពីនេះ មានការ ប្រជុំផ្សេងទៀតទាក់ទងទៅនឹងអង្គការបក្ស ដូចជាការជ្រើសរើសសមាជិកកងទ័ពអាកាស ការ ពង្រាយទ័ពជើងទឹក ការបង្កើនផលិតកម្មអាហារ ការសហការជាមួយអ្នកជំនាញការយោធាចិន និងការបង្កើនការការពារភ្នំពេញ[58]។

---

[56] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុនៃការប្រជុំគណៈកម្មាធិការកងពល៩២០ ពេញអង្គ, ថ្ងៃទី៧-៩-១៩៧៦, ម៉ោង១៤,00, **D1.3.27.14**, ERN 00083157-00083160 (ភាសាខ្មែរ); កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំកម្មាភិបាល ១៦៤ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦, **D1.3.8.4**, ERN 00162488-00162490 (ភាសា ខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ការប្រជុំរបស់សមមិត្ត គាល់, កងពល ២៩០ និងកងពល ១៧០, **D1.3.27.17** ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦, ERN 00002233-00002235 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុនៃការប្រជុំនៅកន្លែងកងពល ១៧០, ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦, **D1.3.8.6**, ERN 00160137-00160141 (ភាសាខ្មែរ); កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ កងពល៩២០, **D1.3.27.24** ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, ERN 00052333-00052335 (ភាសាខ្មែរ); កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ, **D1.3.27.25** ដែលមានចំណងជើងថា កំណត់ហេតុកងពល ៨០១ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, ERN 00052330-00052332 (ភាសាខ្មែរ)។

[57] សុន សេន អាចបានជួបប្រជុំជាមួយកម្មាភិបាលកងពលនីមួយៗ ដែលជាផ្នែកមួយនៃការប្រជុំធម្មតាជាមួយកម្មាភិបាលកងពល។ ឧទាហរណ៍ សុន សេន ប្រជុំជាមួយកងពល ១៧០ និង កងពល ២៩០ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ដែលចំថ្ងៃតែមួយ ដែលគាត់ប្រជុំជាមួយកម្មាភិបាលកងពលទាំងអស់ជុំគ្នា។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងអនុលេខាកងពល និងកងវរឯករាជ្យ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦, ERN 00064954-00064957 (ភាសាខ្មែរ); កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យនៃកងពល ២៩០ និងកងពល ១៧០, **D1.3.27.17** ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦, ERN 00002233-00002235 (ភាសាខ្មែរ)។

ឧទាហរណ៍មួយទៀត, សុន សេន បានប្រជុំដោយឡែកជាមួយកងពល៨០១ និង៩២០ មួយថ្ងៃមុនមានការប្រជុំជាមួយកម្មាភិបាលកងពលទាំងអស់។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំលេខា និងភស្តុភារកងពល និងកងវរឯករាជ្យ, **D1.3.27.23** ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦, ERN 00095507-00095527 (ភាសាខ្មែរ); កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យនៃកងពល ២៩០, **D1.3.27.24** ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, ERN 00052333-00052335 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុកងពល ៨០១, **D1.3.27.25** ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, ERN 00052330-00052332 (ភាសាខ្មែរ)។

[58] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា *ការប្រជុំ ថ្ងៃទី១៨ -៣-១៩៧៦ ស្តីពីការជ្រើសរើសកងអាកាស ថ្ងៃទី* ១៨ ខែមីនា ឆ្នាំ១៩៧៦, **D1.3.8.1**, ERN 00160085-00160085 (ភាសាខ្មែរ); កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ អំពីការវាយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦, **D1.3.8.3** ERN 00021496-00021502 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុនៃការប្រជុំពិភាក្សា ស្តីអំពីជំនាញការកាំភ្លើងធំចិន ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, **D1.3.27.25** ERN 00052330-00052332 (ភាសាខ្មែរ)។ ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណង ជើងថា *កំណត់ហេតុពីការប្រជុំការងារបង្កើនផល*, **D1.3.27.19** ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦, ERN 00088911-00088917 (ភាសាខ្មែរ); កំណត់ហេតុប្រជុំ

24. អគ្គសេនាធិការ បានជួយផ្នែកភស្តុភារដល់កងទ័ពបដិវត្តកម្ពុជា។ ឧទាហរណ៍៖ អគ្គសេនាធិការមានគណៈភស្តុភារមួយដែលមានតួនាទីជួសជុលគ្រឿងយន្ត ជួសជុលអាវុធ ការសាងសង់ ការទុកដាក់សព្វាវុធ និងការដឹកជញ្ជូន[59]។ អគ្គសេនាធិការឃ្លាំមើលស្ថិតិទាក់ទងនឹងផ្នែកយោធា ដូចជាការប្រើប្រាស់ ស្បៀងអាហារ ការចែកអាវុធ និងឧបករណ៍យោធា[60]។ អគ្គសេនាធិការផ្តល់យោបល់ទាក់ទងទៅនឹងផលិតកម្មអាហារ[61]។ ជាចុងក្រោយ អគ្គសេនាធិការទទួលខុសត្រូវលើការអប់រំនយោបាយ នៅតាមកងពល និងកម្មាភិបាលក្នុងកងវរសេនាធំ ហើយបង្កើតកម្មវិធីហ្វឹកហាត់ម្តងម្កាល ដែលត្រូវបានចូលរួមដោយបុគ្គលិកកងទ័ពបដិវត្តកម្ពុជារាប់រយនាក់មកពីទូទាំងប្រទេស[62]។

របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា *កំណត់ហេតុនៃការប្រជុំដកពិសោធន៍ អំពីការឃោមកាមនៅក្នុងការការពារក្រុង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦*, **D1.3.8.9**, ERN 00162477-00162479 (ភាសាខ្មែរ)។

[59] របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា គណៈភស្តុភារសេនាធិការ គោរពជូន បង៨៩ និង ៨១ ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧, **D1.3.9.4**, ERN 00052314-00052314 (ភាសាខ្មែរ) (កម្មាភិបាលដែលចង់ក្បត់នៅក្នុងភស្តុភារសេនាធិការមានមនុស្ស មកពីៈ រោងជាងជួសជុលឡាន, ក្រុមកាប់ឈើ, រោងជាងជួសជុលអាវុធ, ផ្នែកផ្គត់ផ្គង់, ក្រុមសំណង់, ផ្នែកដឹកជញ្ជូនភស្តុភារ, ក្រុមវាស់ស្ទង់របស់ភស្តុភារ, និងឃ្លាំងអាវុធ)។

[60] របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សេនាធិការទ័ពអាកាស បដិវត្តកម្ពុជាៈ ស្ថិតិកម្លាំងហូបរួម-៣ ១៩៧៧, **D1.3.30.10** ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧, ERN 00162476-00162476 (ភាសាខ្មែរ) (ឯកសារសេនាធិការផ្តល់អំពី ស្ថិតិហូបរួមគ្រប់កងពលទាំងអស់)។ របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណង ជើងថា ស្ថិតិអាវុធ និងគ្រាប់សេរដែលស្នើដោយកងពល ៤៥០ និង ៥០២ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦, **D1.3.12.5** ERN 00160097-00160097 (ភាសាខ្មែរ) (ឯកសារសេនាធិការ ដែលមានព័ត៌មានអំពីប្រភេទអាវុធដែលត្រូវការដោយកងពល ៤៥០ និងកងពល ៥០២)។ របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា គំរោងចំណាយស្រូវក្នុងឆ្នាំ ១៩៧៦ តាមអង្គភាព ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦, **D114/27.1.7** ERN 00160081-00160081 (ភាសាខ្មែរ) (ទាញ រៀបរាប់ពីគំរោងចំណាយស្រូវសម្រាប់អង្គភាពកងទ័ព)។ របាយការណ៍កងទ័ព កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា បញ្ជីសម្ភារៈកងទ័ពទទួលពីវៀតណាម, **D1.3.5.23**, ERN 00003678-00003681 (ភាសាខ្មែរ)។ របាយការណ៍ងទ័ពកម្ពុជាប្រជាធិប តេយ្យ ដែលមានចំណងជើងថា ស្ថិតិកងទ័ពជាតិ, កងពល ៣១០ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៧៧, **D1.3.12.19**, ERN 00033313-00033313 (ភាសាខ្មែរ); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា បញ្ជីសម្ភារៈ កងទ័ពទទួលពីវៀតណាម, ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៦, **D114/27.1.3** ERN 00003675-00003677 (ភាសាខ្មែរ)។

[61] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ជូនគណៈកងពល និងវរៈសេនាធំ **D1.3.19.2** ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៧, ERN 00033314-00033314 (ភាសាខ្មែរ)។ (ផ្តល់នូវមតិណែនាំពីសេនាធិការទៅកងពលនៃកងទ័ពបដិវត្តកម្ពុជា ក្នុងផ្នែកធ្វើស្រែ និងប្រាប់អ្នកទាំងនោះឱ្យយកគំរូតាមការខំប្រឹងរបស់កងពល ១៦៤)។

[62] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា តារាងស្ថិតិ សិក្ខាកាមរៀនវគ្គសេនាធិការលើកទី១, **D1.3.30.5** ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦, ERN 00095532-00095543 (ភាសាខ្មែរ)។ របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សិក្ខាកាមរៀនវគ្គសេនាធិការលើកទី១ ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦, **D1.3.8.8**, ERN 00008510-00008534 (ភាសាខ្មែរ)។ របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សិក្ខាកាមរៀនវគ្គសេនាធិការលើកទី២, **D1.3.30.6** ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦, ERN 00008459-00008470 (ភាសាខ្មែរ)។ កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា រាយការណ៍ពីសភាពការណ៍នៅកងពល ៣១០ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ

# កងស្រួច កងតំបន់ និងកងឈ្លប

25. កងទ័ពបដិវត្តកម្ពុជា ត្រូវបានបែងចែកជាបីសាខាៈ“ស្រួច តំបន់ និងឈ្លប”[63]។ កងទ័ព “ស្រួច” មានកងពលធំ និងកងវរសេនាធំឯករាជ្យ ដែលរាយការណ៍ផ្ទាល់ទៅអគ្គសេនាធិការ។ កងពលធំ “តំបន់” រាយការណ៍ទៅគណៈភូមិភាគ ហើយកងវរសេនាធំ “តំបន់” រាយការណ៍ទៅគណៈកម្មាធិការផ្នែក។ កង “ឈ្លប” នៃ ក.ប.ក មាន “ឈ្លប” ឬកងជីវពលតាមមូលដ្ឋាន ដែលរាយការណ៍ទៅកាន់គណៈស្រុក[64]។ គ្រប់កម្រិតនៃយោធារបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវស្ថិតនៅក្រោមបញ្ជាការរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាគ្រប់ពេល[65]។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានលើកឡើងថា “មានតែបក្សទេដែលដឹកនាំកងទ័ព គ្មានអ្នកណាផ្សេងអាចដឹកនាំជំនួសឡើយ”[66]។

26. កងស្រួចនៃកងទ័ពបដិវត្តកម្ពុជា ពេលខ្លះមានកងពលចំនួនពី ៩ ទៅ ១០ (កងពលលេខ ១៦៤, ១៧0, ២៩0, ៣១0, ៤៥0, ៥0២, ៦៩0, ៧0៣, ៨0១, ៩00 និង ៩២0) និងកងវរសេនាធំឯករាជ្យចំនួនបី (កងវរសេនាធំលេខ ១៥២, ៣៧៧ និង ៤៨៨) ព្រមទាំងមន្ទីរជាច្រើនទៀត (ស-២១, ម-៦២ និងម-៦៣)[67]។ មន្ទីរស-២១ ជាអង្គភាពមួយដែលមានតួនាទីចម្បងក្នុងការពង្រឹងសន្តិសុខ

---

១៩៧៦, **D1.3.12.15**, ERN 00160067-00160067 (ភាសាខ្មែរ) (អត់ឃើញមនុស្សពីរនាក់ដែលមានឈ្មោះនៅក្នុងចម្លើយសារភាព “ចូលរួមវគ្គ” ទេ ។ ជាក់ស្តែង នេះគឺយោងដល់វគ្គហ្វឹកហ្វឺនសេនាធិការដែលបន្តធ្វើទៅនៅពេល ជាមួយគ្នា)។

[63] ឯកសារច្បាប់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១៩, **D1.3.22.2** ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦, ERN 00089841-00089852 (ភាសាខ្មែរ); *សូមមើលផងដែរ, ឯកសារច្បាប់នៃ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា, មាត្រា ២៧,* **D1.3.22.1** ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៦, ERN 00053007-00053080 (ភាសាខ្មែរ) (និយាយយោងដល់ផ្នែក៣ដូចគ្នា គឺ ស្រួច តំបន់ និង ឈ្លប)។

[64] លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជាគូសបញ្ជាក់ថា កងពលស្រួចរាយការណ៍ជូនគណៈកម្មាធិការបក្ស សេនាធិការ, កងពលភូមិភាគរាយការណ៍ជូនគណៈកម្មាធិការបក្សភូមិភាគ, វរៈសេនាធំតំបន់រាយ ការណ៍ជូនគណៈកម្មាធិការបក្សតំបន់ ហើយកងឈ្លបស្រុក ឃុំ និង ភូមិរាយការណ៍ជូនគណៈកម្មាធិការ បក្សស្រុក។ សូមមើល, ឯកសារច្បាប់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមានចំណងជើងថា លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា, មាត្រា ១(៣)(ខ), **D1.3.22.1** ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦, ERN 00053007-00053080 (ភាសាខ្មែរ)។

[65] ឯកសារច្បាប់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា, **D1.3.22.1** ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦, ត្រង់ទំព័រ ២៥, ERN 00053007-00053080 (ភាសាខ្មែរ)។

[66] ទស្សនាវដ្តី បកក ដែលមានចំណងជើងថា ទង់បដិវត្ត, **D1.3.24.2** ខែកក្កដា ឆ្នាំ១៩៧៦, ត្រង់ទំព័រ ៦៥, ERN 00062905-00062945 (ភាសាខ្មែរ)។

[67] របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ស្តីពីស្ថិតិកម្លាំងទ័ពសរុប, **D1.3.30.9** ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧, ERN 00052319-00052319 (ភាសាខ្មែរ) (មានបញ្ជីកងពលចំនួន ៩ ក្នុងនោះមាន វរៈសេនាធំឯករាជចំនួន ៣ និងមានមន្ទីរចំនួន ៣ ទៀត នៅក្នុងស្ថិតិកម្លាំងទ័ពនេះ); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កងទ័ពបដិវត្តកម្ពុជានៅសេនាធិការៈ ស្ថិតិកម្លាំងហូបរួម ខែ៣ ១៩៧៧, **D1.3.30.10**

ផ្ទៃក្នុង ត្រូវបានចាត់ទុកថាជាផ្នែកមួយរបស់កងទ័ពបដិវត្តកម្ពុជា ក្នុងគោលបំណងមួយចំនួន[68]។ បើតាមរបាយការណ៍ពីអគ្គសេនាធិការ កង "ស្រួច" របស់អគ្គសេនាធិការមានបុគ្គលិកចំនួនចាប់ពី ៦០,០០០ ទៅ ៦៥,០០០ នាក់[69]។

27. ពេលខ្លះកងពលមជ្ឈិម និងកងទ័ពភូមិភាគស្ថិតនៅក្នុងតំបន់ជាមួយគ្នា។ ឧទាហរណ៍ កងពលមជ្ឈិមលេខ៩២០ មានទីតាំងស្ថិតនៅមូលដ្ឋាននៅតំបន់មណ្ឌលគីរី (តំបន់ ១០៥) ដែលត្រូវបានចាត់ទុកថាជាកងទ័ពស្រួច ខណៈដែលនៅតំបន់មណ្ឌលគីរី មានវរសេនាតូចចំនួន២ ដែលចាត់ទុកថាជា

---

ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧, ERN 00162476-00162476 (ភាសាខ្មែរ) (មានបញ្ជីកងពលចំនួន ៦ ក្នុងនោះមាន វរៈ សេនាធំឯករាជចំនួន ៣ និងមានមន្ទីរចំនួន ៣ បោះទីតាំងនៅភ្នំពេញក្នុងខែ មីនា ឆ្នាំ១៩៧៧); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា តំរោងចំណាយស្រូវក្នុងឆ្នាំ ១៩៧៦ តាមអង្គភាព ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦, **D114/27.1.7**, ERN 00160081-00160081 (ភាសាខ្មែរ) (មានបញ្ជីអង្គភាពចំនួន ១៣ និង មន្ទីរចំនួន ១ នៅក្នុងកងទ័ពបដិវត្តកម្ពុជា)។

[128] សំដីរបស់ **កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.3**, ចុះថ្ងៃទី7 ខែសីហា 2007, ERN 00147526-00147527, ERN 00147517-00147527 (អង់គ្លេស)។ សំដីរបស់ **កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.4**, ចុះថ្ងៃទី24 ខែមិថុនា 2008 ERN 00198221, ERN 00198217-00198225 (អង់គ្លេស)។ មើលផងដែរ, បញ្ជីអ្នក ទោសស-២១, **D1.3.28.140**, ចុះថ្ងៃទី26 ខែវិច្ឆិកា 1978, ERN 00088751-00088753 (ខ្មែរ) (ជនជាតិអាមេរិកពីរនាក់គឺ Christopher Edwards Delance និង Michael Scott Deeds ត្រូវបាននាំមកពីកំពង់សោម)។

[129] ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា *សារទូរស័ព្ទសម្ងាត់ចុះថ្ងៃទី 20/3/78: ជូនចំពោះ បង ៨៩ អំពីស្ថាន ភាពនៅសមុទ្រ*, **D1.3.34.64**, ចុះថ្ងៃទី20 ខែមីនា 1978, ERN 00020982-00020982 (ខ្មែរ) (រៀបរាប់ថាកងទ័ពជើងទឹកកម្ពុជា ប្រជាធិបតេយ្យបានវាយប្រហារលើការណូតបួនគ្រឿង បីជារបស់ថៃ និងមួយជារបស់វៀតណាម។ ការណូតវៀតណាមពី គ្រឿងត្រូវបានពន្លិច ហើយប្រជាជនវៀតណាម៧៦នាក់ត្រូវបានចាប់ខ្លួន។ ថៃ២១នាក់ ក៏ត្រូវបានចាប់ខ្លួនដែរ); របាយការណ៍យោ ធាកម្ពុជាប្រជាធិបតេយ្យ, **D1.3.30.25**, ចុះថ្ងៃទី1 ខែមេសា 1978, ERN 00017026-00017026 (ខ្មែរ) (និយាយថា ការណូត៥ គ្រឿងត្រូវបានចាប់ ហើយជនជាតិវៀតណាមចំនួន១២០នាក់ ត្រូវបានចាប់ និងសម្លាប់រវាងថ្ងៃទី២៧ និង៣០ ខែមីនា 1978)។

នៅសមុទ្រ[130]។ សាក្សីម្នាក់បានបញ្ជាក់ថា ប្រជាជនវៀតណាមជា"ច្រើន" នាក់ត្រូវបានចាប់ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ រួចបញ្ជូនទៅទីបញ្ជាការកងពល១៦៤[131]។ ប្រជាជនមួយចំនួនដែលត្រូវគេយល់ថាជា "គិញវៀតណាម" ហើយមានឈ្មោះវៀតណាម ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ពីកងពលធំលេខ ១៦៤ និងពីកំពង់សោម[132]។ យ៉ាងហោចណាស់អ្នកទោស វៀតណាមខ្លះនៅមន្ទីរស-២១ ជាអ្នកនេសាទដែលត្រូវបានចាប់ពេលកំពុងនេសាទនៅក្នុងផ្ទៃទឹក ក្បែរព្រំដែនវៀតណាម[133]។ លើសពីនេះ តាមការសង្កេត ហាក់ដូចជាបង្ហាញថាអ្នកទោសខ្លះ ដែលបានសារភាពថាជាទាហានវៀតណាម ឬក៏ជាគិញវៀតណាម តាមការពិតជាជនស៊ីវិលវៀតណាម ដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាន[134]។

---

[130] អត្ថបទកាសែ អត្ថបទកាសែត មានចំណងជើងថា *កងទ័ពជើងទឹកកម្ពុជារក្សាការប្រុងប្រយ័ត្ន*, **D1.3.25.40** ចុះថ្ងៃទី30 ខែមីនា 1978 ERN S 00010450, ERN S 00010448-00010453 (អង់គ្លេស) (សរសេរថា"ភ្នាក់ងារវៀតណាមត្រូវបានចាប់នៅសមុទ្រ នៅថ្ងៃទី៣, ១៨ និង២៥ ខែមករា និងថ្ងៃទី១ ខែកុម្ភៈ 1978")។

[131] សំដីរបស់សាក្សី ក.ស.ព-**00153** កំណត់ត្រាសម្ភាសន៍របស់ ក.ស.ព, **D1.3.13.13**, ចុះថ្ងៃទី16 ខែសីហា 2008, ERN00217574, ERN 00217569-00217575 (អង់គ្លេស)។

[132] បញ្ជីអ្នកទោសស-២១, **D1.3.28.5**, ERN 00040773-00040775 (ខ្មែរ) (បង្ហាញថា "យួន" ១០នាក់ ត្រូវបានចាប់ពីកំពង់សោមនៅថ្ងៃទី 1 ខែឧសភា 1978 ហើយ"យួន" ត្រូវបានចាប់ដោយកងពល១៦៤ ក្នុងថ្ងៃតែមួយ)។

[133] សំដីរបស់ **ឈុំ ផល** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.32.9** ចុះថ្ងៃទី18 ខែកុម្ភៈ 2008, ត្រង់ ERN 00163814, ERN 00163811-00163815 (អង់គ្លេស) (សរសេរថា យ៉ាងហោចអ្នកទោសវៀតណាមម្នាក់ ដែលបានចាប់ទៅស-២១នៅឆ្នាំ១៩៧៨ អះអាងថាជាអ្នកនេសាទ មិនមែនជាទាហានទេ ហើយគាត់ត្រូវគេចាប់ពេលកំពុងនេសាទ)។
ចម្លើយសារភាពរបស់អ្នកទោសវៀតណាមខ្លះនៅ ស-២១ បញ្ជាក់ថាពួកគេត្រូវបានចាប់ខ្លួនដោយកងទ័ពជើងទឹក ហើយផ្ទេរទៅ ស-២១ដោយ កងពល ១៦៤។ ចម្លើយសារភាពនៅ ស-២១ របស់ VINH Seang ដែលជាទាហានវៀតណាម ម្នាក់ចាប់ខ្លួននៅខែមីនា 1978 មានចំណារដៃមួយបង្ហាញថា VINH Seang ជាគិញម្នាក់ នៃគិញមួយក្រុម ដែលត្រូវបានចាប់មកពីព្រែកជីក Vin Te និង តំបន់នៅជិត កោះឫស្សីក្នុងផ្ទៃទឹកកម្ពុជា។ ចំណារនេះបញ្ជាក់ថាកងពល១៦៤ជាអ្នកចាប់។ ចម្លើយសារភាពនៅ ស-២១ របស់ **VINH Seang, D1.3.1.14,** ចុះថ្ងៃទី 23 ខែមីនា 1978, ERN 00052936-00052948 (ខ្មែរ)។ ដូចបានបង្ហាញនៅក្នុងចម្លើយសារភាពនៅ ស-២១ របស់គាត់ VINH Minhchov ដែលជាទាហានជើងទឹកពិសេសរបស់វៀតណាម ត្រូវបានចាប់ខ្លួននៅថ្ងៃទី 13 ខែមីនា 1978 នៅកោះអង្រុង នៃប្រទេសកម្ពុជា។ ទំព័រចុងក្រោយនៃចម្លើយសារភាពនេះគឺជាការដកស្រង់មកពីបញ្ជីអ្នកទោសស-២១ ដែលបង្ហាញឱ្យឃើញថារូបគាត់និងអ្នកទោសវៀតណាម៦នាក់ទៀតត្រូវបានគេបញ្ជូនពIកំពង់សោមមកមន្ទីរ ស-២១ ទីកន្លែងតចាប់ខ្លួនគាត់ ក៏ដូចជាការពិតនៃការបញ្ជូនអ្នកទោសវៀតណាមទាំងនោះពីកំពង់សោមមកកាន់មន្ទីរស-២១នោះគឺបង្ហាញថា កងពលធំលេខ១៦៤ បានចូលរួមនោះក្នុងការចាប់ខ្លួនគាត់។ ចម្លើយសារភាពនៅស-២១ របស់ **វិញ មិញចូវ , D1.3.1.13,** ចុះថ្ងៃទី 3 ខែមេសា 1978, ERN 00052923-00052935 (ខ្មែរ)។

[134] *មើល* អត្ថបទកាសែត ដោយ សេចក្តីសង្ខេបព័ត៍មានពិភពលោករបស់BBC, មានចំណងជើងថា *Confession of a captured SRV sailor*, **D1.3.26.5** ចុះថ្ងៃទី 3 ខែកុម្ភៈ 1978, ERN S 00008895, ERN S 00008892-00008899 (អង់គ្លេស) (សរសេរថា មនុស្សម្នាក់ដែលបានសារភាពថាជានាវិកវៀតណាម ត្រូវបានចាប់ដោយកងទ័ពកម្ពុជាជាមួយនិង មនុស្សប្រហែល៤០ទៀត ក្នុងនោះ២៥នាក់ជាកុមារ ដែលដំបូងអះអាងថាជា "ជនភាសខ្លួនសង្គ្រាម")។ អត្ថបទកាសែត ដោយ សេចក្តីសង្ខេបព័ត៍មានពិភព

## ទំនាក់ទំនងរវាងកងពល និងគណៈមជ្ឈិមបក្ស

42. អៀង សារី បានបញ្ជាក់ថា គណៈកម្មាធិការយោធា ជាទូទៅ រាយការណ៍ទៅគណៈកម្មាធិការ អចិន្ត្រៃយ៍ បន្ទាប់ពីទទួលបានរបាយការណ៍ពីភូមិភាគ ហើយគាត់ក៏ធ្លាប់បានដឹងដោយផ្ទាល់អំពីរបាយការណ៍សន្តិសុខ។[135] ទំនាក់ទំនងនេះត្រូវបានធ្វើឡើងជាប្រចាំ ដោយច្រើនដងក្នុងមួយថ្ងៃៗ។[136] អង្គភាពបញ្ជាការនៅថ្នាក់មជ្ឈិមបានទំនាក់ទំនងការងារជាទៀងទាត់ជាមួយនឹងកងពលនានា[137] ដោយផ្អែកលើកងពលទាំងនេះហើយដើម្បីបញ្ជូនបន្តនូវបញ្ហាទៅកាន់អង្គភាពផ្សេងៗទៀត ដែលមានថ្នាក់ទាបជាង។ សេចក្តីសម្រេចសំខាន់ៗរបស់កងពល ត្រូវបានធ្វើឡើងដោយថ្នាក់ មជ្ឈិ

---

លោករបស់BBC, មានចំណងជើងថា *ចម្លើយសារភាពរបស់ប្រជាជនវៀតណាមដែលគេចាប់*, **D1.3.26.9** ចុះថ្ងៃទី 19 ខែឧសភា 1978, ERN 00010018, ERN S 00010014-00010019 (អង់គ្លេស) (សរសេរថាបុរសវៀតណាមម្នាក់ "ក្លែងខ្លួនជាអ្នកនេសាទ"ត្រូវបានចាប់ខ្លួននៅក្នុងផ្ទៃទឹកកម្ពុជា ហើយក្រោយមកបានសារភាពថាទទួលបញ្ជារឱ្យស៊ើបការនៅកម្ពុជា); អត្ថបទកាសែត ដោយ សេចក្តីសង្ខេបព័ត៌មានពិភពលោករបស់ BBC, មានចំណងជើងថា *ចម្លើយសារភាពរបស់តិញវៀតណាម* , **D1.3.7.3**, ចុះថ្ងៃទី4 ខែមេសា 1978, ERN S 00010313-00010313 (អង់គ្លេស) (*សរសេរថាមនុស្សម្នាក់ ដែលបានសារភាពថា ជាពលឯកវៀតណាមបានអះអាងថាខ្លួនជាជនជាតិចិនព្យាយាមគេចខ្លួនទេ ទៅម៉ាឡេស៊ីតាមទូកនេសាទ*)។

[135] ឯកសារ **D4.1.1032** បទសម្ភាសន៍ អៀង សារី នៅទីក្រុងញូវយ៉ក បេសកម្មរបស់អង្គការសហប្រជាជាតិនៃកម្ពុជាប្រជាធិបតេយ្យ ដោយលោកស្រី Elizabeth Becker ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៨១ ទំព័រ៥។

[136] ឯកសារ **D4.1.845** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡាញ ឌុស** ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២00៩ ទំព័រ៥-៦។ ឯកសារ **D4.1.925** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ប៉ុល ញ៉ិន** ថ្ងៃទី៣១ ខែសីហា ឆ្នាំ២00៩ ទំព័រ៧។

[137] ឯកសារ **D4.1.855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡាញ ឌុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៩ ទំព័រ៣។ ឯកសារ **D4.1.848** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឈូក រីន** ហៅ សុខ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២00៩ ទំព័រ៥។ ឯកសារ **D4.1.408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឈូក រីន** ហៅ សុខ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២00៨ ទំព័រ៦ និង៨។ ឯកសារ **D4.1.925** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ប៉ុល ញ៉ិន** ថ្ងៃទី៣១ ខែសីហា ឆ្នាំ២00៩ ទំព័រ៧។ ឯកសារ **D4.1.1056** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ជួន ធី** ហៅ **ធីធី** ថ្ងៃទី0២ ខែមីនា ឆ្នាំ២0១0 ទំព័រ៩។ ឯកសារ **D1.3.30.3** របាយការណ៍របស់ **មុត** មានចំណងជើងថា "សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ថ្ងៃទី0៥ ខែមករា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.12.3** របាយការណ៍របស់ **មុត** ជម្រាបជូនបង ៨៩ គោរពជ្រាប" ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ **D1.3.8.4** កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃទី0៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.4.1** សំបុត្រផ្ញើពី **មុត** មានចំណងជើងថា "ជម្រាប បង ៨៩ គោរពជ្រាប" ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.2.2** ទូរលេខ លេខ១0 របស់បង ៨៩ ផ្ញើជូន សមមិត្ត **មុត** ជាទីស្នេហា និងនឹករលឹក ថ្ងៃទី0៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.4.2** ទូរលេខ លេខ១0 របស់បង ៨៩ ផ្ញើជូន សមមិត្ត ឌឹម ជាទីស្នេហា និងនឹករលឹក ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.12.18** ទូរលេខ លេខ៩ របស់ **មុត** ផ្ញើជូន បង ៨៩ ជាទីគោរព ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.34.23** ទូរលេខ លេខ២៨ របស់ សឿង ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.34.10** ទូរលេខ លេខ៤៤ របស់ **មុត** ផ្ញើជូន បង ៨៩ គោរពជ្រាប ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.34.64** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** ជូន បង ៨៩ ថ្ងៃទី២0 ខែមីនា ឆ្នាំ១៩៧៨។

ម។[138] កងពលផ្ញើសេចក្ដីរាយការណ៍ទៅថ្នាក់មជ្ឈិមទៀងទាត់ ជាទូទៅរាយការណ៍អំពីការប្រយុទ្ធគ្នា ការរកឃើញខ្មាំងផ្ទៃក្នុង និងបញ្ហាផ្សេងៗទៀត។[139]

43. ទំនាក់ទំនងការងារត្រូវបានសម្របសម្រួលតាមមធ្យោបាយជាច្រើន។ ទំនាក់ទំនងដែលប្រើប្រាស់ញឹកញាប់ គឺតាមរយៈវិទ្យុទាក់ទង សារទូលេខ។[140] ដើម្បីសម្រេចគោលបំណងនេះ សេនាធិការ ក៏ដូចជាកងពលនានាដែរ មានអង្គភាពវិទ្យុទាក់ទង និងអង្គភាពសារទូលេខ។ សារត្រូវបានធ្វើជាសម្ងាត់។[141] ជាទូទៅ និរសាត្រូវបានប្រើប្រាស់ជាញឹកញាប់ផងដែរ ដើម្បីបញ្ជូនសារ[142] ហើយកង

---

[138] ឯកសារ **D4.1.925** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ប៊ុល ញ៉ិន** ថ្ងៃទី៣១ ខែសីហា ឆ្នាំ២00៩ ទំព័រ៧។

[139] ឯកសារ **D4.1.855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ឡុញ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៩ ទំព័រ៣។ ឯកសារ **D4.1.848** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ឈួក រីន** ហៅ សុខ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២00៩ ទំព័រ៥។ ឯកសារ **D4.1.925** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ប៊ុល ញ៉ិន** ថ្ងៃទី៣១ ខែសីហា ឆ្នាំ២00៩ ទំព័រ៧។ ឯកសារ **D4.1.1056** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ជួន ធី** ហៅ **ធីឌី** ថ្ងៃទី0២ ខែមីនា ឆ្នាំ២0១0 ទំព័រ៩។ ឯកសារ **D4.1.1042** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **មាស វឿន** ហៅ **ស្វាយ វឿន** ថ្ងៃទី0៤ ខែមីនា ឆ្នាំ២0១0 ទំព័រ៣។ ឯកសារ **D1.3.30.2** របាយការណ៍របស់ **មុត** មានចំណងជើងថា "សូមគោរពរាយការណ៍ជូន បង ៨៩ ជ្រាប" ថ្ងៃទី0៥ ខែមករា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.12.3** សេចក្ដីរាយការណ៍របស់ **មុត** មានចំណងជើងថា "ជម្រាបជូន បង ៨៩ គោរពជ្រាប" ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ **D1.3.8.4** កំណត់ហេតុនៃការប្រជុំ សមមត្ដិ ១៦៤ ថ្ងៃទី0៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.4.1** សំបុត្រផ្ញើពី **មុត** មានចំណងជើងថា "សូមគោរពជូន បង ៨៩ ជ្រាប" ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.2.2** ទូរលេខ លេខ១0 របស់បង ៨៩ ផ្ញើជូន សមមិត្ត **មុត** ជាទីស្នេហា និងនឹករលឹក ថ្ងៃទី0៤ ខែវិច្ឆកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.34.64** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** ជូន បង ៨៩ ថ្ងៃទី២0 ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D1.3.4.2** ទូរលេខ លេខ១0 របស់បង ៨៩ ផ្ញើជូន សមមិត្ត ឌឹម ជាទីស្នេហា និងនឹករលឹក ថ្ងៃទី២៦ ខែវិច្ឆកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.12.18** ទូរលេខ លេខ៩ របស់ **មុត** ផ្ញើជូន បង ៨៩ ជាទីគោរព ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.34.23** ទូរលេខ លេខ២៨ របស់ សឿង ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.9.1** របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា "សេចក្ដីរាយការណ៍អំពីស្ថានភាពក្នុងកងពល ៤៥0" ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

[140] ឯកសារ **D4.1.855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ឡុញ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៩ ទំព័រ៣។ ឯកសារ **D4.1.408** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ឈួក រីន** ហៅ សុខ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២00៨ ទំព័រ៦។ ឯកសារ **D4.1.1139** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ប៊ុល លាង** ថ្ងៃទី១៧ ខែមករា ឆ្នាំ២00៨ ទំព័រ៣។ ឯកសារ **D4.1.1142** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ថា សុត** ថ្ងៃទី១៩ ខែមករា ឆ្នាំ២00៨ ទំព័រ៣។ ឯកសារ **D4.1.851** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **មាស វឿន** ហៅ **ស្វាយ វឿន** ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២00៩ ទំព័រ៥។ ឯកសារ **D4.1.1153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **សែម អំ** ហៅ **ព្រំ អៀត** ថ្ងៃទី0៥ ខែមីនា ឆ្នាំ២00៨ ទំព័រ៤។ ឯកសារ **D4.1.1056** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ជួន ធី** ហៅ **ធីឌី** ថ្ងៃទី0២ ខែមីនា ឆ្នាំ២0១0 ទំព័រ៩។ ឯកសារ **D4.1.803** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ជិន គីមថុង** ហៅ **ឆាង** ថ្ងៃទី0៣ ខែវិច្ឆិកា ឆ្នាំ២00៩ ទំព័រ៣-៤។

[141] ឯកសារ **D4.1.855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ឡុញ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៩ ទំព័រ២-៣។

[142] ឯកសារ **D4.1.837** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី **ហែម សុផល** ហៅ **ឈុំ** ថ្ងៃទី៣១ ខែសីហា ឆ្នាំ២00៩ ទំព័រ៤។

ពលនីមួយៗ មានអង្គភាពនិរសាដើម្បីធ្វើការងារនេះ។[143] សារទំនាក់ទំនងរវាងសេនាធិការ ឬកងពលនានា ជាមួយនឹងគណៈកម្មាធិការឃោធា ត្រូវបញ្ជូនផងដែរទៅឲ្យសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស។[144]

44. កិច្ចប្រជុំផ្ទាល់ជាមធ្យោបាយដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីទាក់ទងការងាររវាងអង្គភាពបញ្ជាការរបស់មជ្ឈិម និងកងពលនានា។[145] ការប្រជុំទាំងនេះ អាចមានការប្រជុំទ្រង់ទ្រាយតូច[146] ឬធំ[147]។ ជាក់ស្តែង ការប្រជុំធំហើយសំខាន់ ដូចជាការប្រជុំមុនវាយចូលភ្នំពេញផ្តាច់

[143] ឯកសារ **D4.1.848** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឈូក រីន** ហៅ សុខ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ៥។ ឯកសារ **D4.1.846** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **អៀង ផាន** ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ៦។ ឯកសារ **D4.1.845** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡុញ ដុស** ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ៥។ ឯកសារ **D4.1.1056** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ជួន ធី** ហៅ **ធីឌី** ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ទំព័រ៩។

[144] ឯកសារ **D4.1.806** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ជាំង ស្រីមុំ** ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ៤។

[145] ឯកសារ **D4.1.803** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ជិន គឹមថុង** ហៅ **ឆាង** ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ២-៣។

[146] ឯកសារ **D4.1.782** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **សួន កានិល** ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ ទំព័រ៣។ ឯកសារ **D1.4.699** ទូរលេខ លេខ១១ របស់សមមិត្ត ឌឹម ផ្ញើជូនបង មុត ជ្រាប ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ (ចម្លងជូនៈបងៗ បង នួន បង ខៀវ និងមន្ទីរ-ឯកសារ)។ ឯកសារ **D1.3.34.39** ទូរលេខ លេខ០៤ ៤២៩ខ្ទង់ របស់ រឿន ផ្ញើជូនបង មុត គោរពស្នេហា ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

[147] ឯកសារ **D4.1.408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឈូក រីន** ហៅ សុខ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ ទំព័រ៥-៧។ ឯកសារ **D4.1.837** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ហែន សុផល** ហៅ ឈុំ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ទំព័រ៤។ ឯកសារ **D4.1.855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡុញ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៣។ ឯកសារ **D1.3.27.10** កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខវរសេនាធំ ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.11** កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.12** កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខវរសេនាធំ ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.13** កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខវរសេនាធំ ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.30.6** របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា "តារាងស្ថិតិសិក្ខាកាមវគ្គសេនាធិការលើកទី២" ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.20** កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.21** កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.22** កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.26** កំណត់ហេតុនៃការប្រជុំលេខាកងពល អនុលេខា និងវរសេនាធំឯករាជ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.27.17** កំណត់ហេតុនៃការប្រជុំសមមិត្ត តាល់ កងពល ២៩០ និងកងពល ១៧០ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.24** កំណត់ហេតុនៃការប្រជុំកងពល ២៩០ សមមិត្ត សយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.25** កំណត់ហេតុនៃការប្រជុំកងពល ៨០១ សមមិត្ត សឿន និង ធី ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦។

ព្រ័ត្រ[148] ឬមុនពេលបោសសម្អាតភូមិភាគបូព៌ា[149]។ ការប្រជុំធំ មានការធ្វើសន្ទរកថាដោយមេដឹកនាំបក្ស។[150] សាក្សីបានផ្តល់សក្ខីកម្មថា មានការប្រជុំផ្នែកយោធានៅពហុកីឡាដ្ឋានអូឡាំពិកក្នុងទីក្រុងភ្នំពេញ មានការចូលរួមពីមេបញ្ជាការអង្គភាពនានា ថ្នាក់វរសេនាតូចឡើងទៅ ដោយមាន សុន សេន ជាអ្នកដឹកនាំការប្រជុំ។[151]

45. កងពលលេខ១៦៤ គឺជាកងពលមួយស្ថិតក្រោមការគ្រប់គ្រងរបស់មជ្ឈិម[152] ហើយទទួលបន្ទុកការងារយោធា រួមមាន ផ្គត់ផ្គង់សម្ភារៈ ភស្តុភារ អាវុធ ទាហាន ទំនាក់ទំនង និងព័ត៌មាន។[153] **មាស មុត** ក្នុងនាមជាលេខាកងពលលេខ១៦៤ បានរាយការណ៍ផ្ទាល់ទៅសេនាធិការ[154] ក្នុងករណីមាន

[148] ឯកសារ **D1.3.8.3** កំណត់ហេតុនៃការប្រជុំការងារយោធានៅកំពង់សោម ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦។

[149] ឯកសារ **D4.1.1151** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ប្រាក់ យឿន** ហៅ អ៊ី ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨ ទំព័រ៤។ ឯកសារ **D4.1.509** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ខឹម សំហួន** ហៅ គួច ហៅ អួន ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ ទំព័រ៥។

[150] ឯកសារ **D4.1.851** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **មាស វឿន** ហៅ ស្វាយ វឿន ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ទំព័រ៣។ ឯកសារ **D4.1.827** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ហ៊ឹម ហ៊ាន** ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ទំព័រ៣។ ឯកសារ **D4.1.504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **កែវ គឹន** ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ៣។

[151] ឯកសារ **D4.1.409** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឈួក រីន** ហៅ សុខ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ៤។ ឯកសារ **D4.1.848** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឈួក រីន** ហៅ សុខ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ៣។

[152] ឯកសារ **D4.1.1151** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ប្រាក់ យឿន** ហៅ អ៊ី ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨ ទំព័រ៤។ ឯកសារ **D4.1.509** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ខឹម សំហួន** ហៅ គួច ហៅ អួន ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ ទំព័រ៥។ ឯកសារ **D4.1.805** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **សោម សែ** ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ទំព័រ៤។ ឯកសារ **D4.1.454** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **កុយ ម៉ុន** ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ទំព័រ៣។

[153] ឯកសារ **D4.1.240** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **អឿន តាន** ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ទំព័រ៥-៦។ ឯកសារ **D1.3.27.8** កំណត់ហេតុនៃការប្រជុំលេខា និងសេដ្ឋកិច្ចកងពល ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.10** កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល លេខា និងអនុវរសេនាធំ ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.11** កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.12** កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.30.6** របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា "តារាងស្ថិតិសិក្ខាកាមវគ្គសេនាធិការលើកទី២" ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.20** កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.21** កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.22** កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.23** កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦។ ឯកសារ **D1.3.27.26** កំណត់ហេតុនៃការប្រជុំលេខាកងពល អនុលេខា និងវរសេនាធំឯករាជ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧។

[154] ឯកសារ **D4.1.855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡាញ់ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៣។

ការល្អានពានរបស់បរទេសចូលក្នុងកម្ពុជាប្រជាធិបតេយ្យ មានន័យថា រាយការណ៍ទៅថ្នាក់លើភ្លាម ហើយរង់ចាំទទួលបញ្ជាពីថ្នាក់លើមកវិញ។[155]

46. ឧទាហរណ៍ជាក់ស្តែង **មាស មុត** បានរាយការណ៍អំពីជម្លោះប្រដាប់អាវុធជាមួយវៀតណាមនៅកោះត្រល់[156] និងអំពីចំនួនខ្មាំងដែលចាប់បានទៅកាន់ សុន សេន ដោយផ្ទាល់ បន្ទាប់មក សុន សេន ជាអ្នករាយការណ៍ទៅថ្នាក់លើបន្ត។[157] **មាស មុត** បានរាយការណ៍ "យើង...ចាប់បានទូក២គ្រឿង។ ........ចាប់បាននៅកៀកកោះកុងប្រហែល២គ.ម។ ក្រោយមកយើងសាកសួរ..... ទាំង៥នាក់ មានខ្មែរម្នាក់ និងសៀម។[158]" លើសពីនេះ សុន សេន បានចារនៅលើសេចក្តីរាយការណ៍ថា "ជូន អ/ក យើងខ្ញុំស្វែងរកខ្សែខាងក្នុង រកផ្លូវចេញចូល សភាពការណ៍ពួកអាក្បត់នៅតាមព្រំដែន។[159]"

47. ក្នុងករណីនេះ **មាស មុត** បានរាយការណ៍ទៅ សុន សេន អំពីចាប់បានអ្នកនេសាទថៃ[160] ការបោសសម្អាតក្នុងអង្គភាព[161] និងសភាពការណ៍យោធា[162]។ **មាស មុត** បានរាយការណ៍ទៅគណៈមជ្ឈិម

---

[155] ឯកសារ **D4.1.855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡាញ់ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៩ ទំព័រ៣។ ឯកសារ **D4.1.520** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **កែ ពេជ្រវណ្ណៈ** ហៅ វណ្ណៈ ហៅ យុទ្ធ ថ្ងៃទី0៤ ខែមិថុនា ឆ្នាំ២00៩ ទំព័រ៨។ ឯកសារ **D1.3.9.4** របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា "គណៈភស្តុភារសេនាធិការជូនចំពោះបង ៨៩ និង ៨១" ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧។

[156] ឯកសារ **D12** កំណត់ហេតុនៃសួរចម្លើយជនត្រូវចោទ **កាំង ហ្កេចអ៊ាវ** ហៅ **ឌុច** ថ្ងៃទី២៧ ខែមេសា ឆ្នាំ២0១១ ទំព័រ៤។ ឯកសារ **D1.3.13.13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ទូច សឿលី** ហៅ **សឿ ទូច** ថ្ងៃទី១៦ ខែសីហា ឆ្នាំ២00៨ ទំព័រ៦ (ភាសាអង់គ្លេស)។

[157] ឯកសារ **D2/10** កំណត់ហេតុនៃស្តាប់ចម្លើយសាក្សី **សយ ប៊ន** ថ្ងៃទី0៩ ខែកញ្ញា ឆ្នាំ២0១0 ទំព័រ៧-៨។

[158] ឯកសារ **D1.3.30.2** របាយការណ៍របស់ **មាស មុត** មានចំណងជើងថា "សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ថ្ងៃទី0៥ ខែមករា ឆ្នាំ១៩៧៦។

[159] ឯកសារ **D1.3.12.20** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** សេចក្តីរាយការណ៍ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.12.18** ទូរលេខ លេខ0៩ របស់ មុត ផ្ញើទៅកាន់បង ៨៩ ជាទីគោរពជ្រាប ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧។

[160] ឯកសារ **D1.3.12.20** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** សេចក្តីរាយការណ៍ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧។

[161] ឯកសារ **D1.3.12.20** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** សេចក្តីរាយការណ៍ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧។

[162] ឯកសារ **D1.3.30.4** សរុបសភាពការណ៍ ចាប់ពីថ្ងៃទី១៥ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦។

បក្ស តាមរយៈសារទូរលេខ[163] ទូរស័ព្ទ[164] សំបុត្រ[165] និងនិរសា[166]។ សារទូរលេខ សំបុត្រ និងសេចក្តីរាយការណ៍របស់ **មាស មុត** បានផ្ញើជូន សុន សេន ហើយបានចម្លងជូន នួន ជា វ៉ន វ៉េត បង ណាត បងសោម សៀត ឆែ និងបងកាត[167] ហើយក៏បានរាយការណ៍ផងដែរអំពីការដាំដុះស្រូវ[168] និងសុខភាពរបស់កងទ័ព[169]។

---

[163] ឯកសារ **D1.3.27.26** កំណត់ហេតុនៃការប្រជុំលេខាកងពល អនុលេខា និងវរសេនាធំឯករាជ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧ ទំព័រ ២។

[164] ឯកសារ **D1.3.8.3** កំណត់ហេតុនៃការប្រជុំការងារយោធានៅកំពង់សោម ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ ទំព័រ១-២។

[165] ឯកសារ **D4.1.1020** ទូរលេខរបស់ **មុត** ផ្ញើទៅបង ៨៩ គោរពជ្រាប ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ **D1.3.34.10** ទូរលេខ លេខ៤៤ របស់ **មុត** ផ្ញើជូនបង ៨៩ គោរពជ្រាប ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.30.2** របាយការណ៍របស់ **មុត** មានចំណងជើងថា "សូមគោរពរាយការណ៍ជូន បង ៨៩ ជ្រាប" ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។ ឯកសារ **D1.3.12.3** សេចក្តីរាយការណ៍របស់ **មុត** ជម្រាបជូន បង ៨៩ គោរពជ្រាប" ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ **D1.3.14.1** ទូរលេខ របស់ **មុត** ផ្ញើទៅកាន់បង ៨៩ គោរពជ្រាប ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ ៖ (មុត រាយការណ៍ពីការចាប់បានសំបុត្រ ដែលផ្ញើជូនចំពោះឈ្មោះសំអាត អនុលេខានៃកងវរសេនាតូច ១៦៥ និងឈ្មោះ ប៊ុននី ឬស៊ុននី អនុលេខានៃកងវរសេនាធំ និងបានស្នើសុំយោបល់ សុន សេន ថា "ចំពោះបញ្ហានេះ សុំយោបល់អង្គការសម្រេចយ៉ាងណា ព្រោះតាមមើលច្បាស់គួរសមដែរ")។ ឯកសារ **D1.3.12.18** ទូរលេខ លេខ០៩ របស់ **មុត** ផ្ញើជូនបង ៨៩ គោរពជ្រាប ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.2.2** ទូរលេខ លេខ១០ របស់បង ៨៩ ទៅកាន់សមមិត្ត **មុត** ជាទីស្នេហា និងនីករលឹក ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ **D4.1.855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡុញ ដុស** ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៣។ ឯកសារ **D1.3.12.2** សេចក្តីរាយការណ៍របស់ **មុត** ជម្រាបជូន បង ៨៩ គោរពជ្រាប" ថ្ងៃទី០៦ ខែកុម្ភៈ មិនមានកំណត់ឆ្នាំ។ ឯកសារ **D1.3.14.2** សារតាមទូរស័ព្ទសម្ងាត់របស់ មឿន ផ្ញើជូនសមមិត្ត **មុត** ស្នេហាជ្រាប ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៧។ ឯកសារ **D1.3.34.60** ទូរលេខ លេខ០០ ៣៥៩ខ្ទង់ របស់ **មុត** ផ្ញើទៅកាន់គណៈម៨៧០ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។

[166] ឯកសារ **D1.3.34.64** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** ផ្ញើជូនបង ៨៩ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ **D1.3.30.25** សារតាមទូរស័ព្ទសម្ងាត់របស់ មុត សេចក្តីរាយការណ៍របស់កងពល ១៦៤ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ **D1.3.637** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** ផ្ញើជូនបង ៨៩ ថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ **D1.3.12.20** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** សេចក្តីរាយការណ៍ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧។

[167] ឯកសារ **D1.3.30.25** សារតាមទូរស័ព្ទសម្ងាត់របស់ **មុត** សេចក្តីរាយការណ៍របស់កងពល ១៦៤ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨។

[168] ឯកសារ **D1.3.4.1** សំបុត្រផ្ញើពី **មុត** មានចំណងជើងថា "ជម្រាប បង ៨៩ គោរពជ្រាប" ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **D4.1.1010** សំបុត្រផ្ញើពី កន និង **មុត** មានចំណងជើងថា "ជូន បង ៨៩ គោរព" អំពីសំណើរបស់លោកស្រី Elizabeth Becker ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៨។

[169] ឯកសារ **D1.3.4.1** សំបុត្រផ្ញើពី **មុត** មានចំណងជើងថា "ជម្រាប បង ៨៩ គោរពជ្រាប" ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ **D4.1.1020** ទូរលេខរបស់ **មុត** "ផ្ញើជូន បង ៨៩ គោរពជ្រាប" ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦។

## សាវតាររបស់ មាស មុត

48. **មាស មុត** មានឈ្មោះកំណើត ខែ មុត បានកើតនៅក្នុងខេត្តតាកែវ[170] ឬ ខេត្តកំពត[171]។ គាត់ជា កូនប្រសារច្បងរបស់ ឈិត ជឿន ហៅ តាម៉ុក[172] អតីតលេខាភូមិភាគនិរតីពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

49. បន្ទាប់ពីបានចូលរួមជាមួយចលនាខ្មែរក្រហមនៅឆ្នាំ១៩៧០ **មាស មុត** ត្រូវបានចាត់តាំងឲ្យធ្វើជាពេទ្យយោធា។ គាត់ត្រូវបានទទួលការងារដំបូងនៅក្នុងភូមិពោធិ៍ ហើយបន្ទាប់មកទៀតនៅក្នុងស្រុងអង្គរជ័យ (ស្រុក១០២) ស្ថិតក្នុងតំបន់១៣[173]។ នៅចុងឆ្នាំ១៩៧០ ឬដើមឆ្នាំ១៩៧១ **មាស មុត** បានក្លាយជាមេបញ្ជាការរងយោធាស្រុកអង្គរជ័យ ដែលនៅទីនោះ គាត់បានគ្រប់គ្រងកងទ័ពប្រហែល ២០០នាក់[174]។ ក្រោយមក **មាស មុត** ត្រូវបានតែតាំងជាគណៈកម្មាធិការតំបន់១៣ ក្នុងភូមិភាគនិរតី[175] ដែលនៅទីនោះ គាត់ទទួលបន្ទុកខាងយោធាដល់ឆ្នាំ១៩៧៣[176]។ ក្នុងពេលនោះ **មាស មុត** ត្រូវបានបញ្ចូលជាសមាជិកពេញសិទ្ធិរបស់បក្សកុម្មុយនីស្តកម្ពុជា[177]។

---

[170] សំដីរបស់ **មាស ចាន់ណា** ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, **D1.3.32.28** ចុះថ្ងៃទី 21 ខែមិថុនា 2004, , ERN 00019495-00019496 (ខ្មែរ)។

[171] សំដីរបស់សាក្សី ក.ស.ព-00143 កំណត់ត្រាសម្ភាសន៍របស់ ក.ស.ព, D1.3.13.1 ចុះថ្ងៃទី 12 ខែសីហា 2008, ERN00217558, ERN 00217556-00217558 (អង់គ្លេស)។(បង្ហាញថា មាស មុត មកពីស្រុក ជុំគីរី ខេត្តកំពត)។

[172] សំដីរបស់ **ខៀវ សំផន** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.15,** ចុះថ្ងៃទី13 ខែធ្នូ, ERN 00156751, ERN 00156741-00156751 (អង់គ្លេស)។ សាក្សី ក.ស.ព-00117 កំណត់ត្រាសម្ភាសន៍របស់ ក.ស.ព, **D1.3.13.8,** ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០០៨ ERN 00217562, ERN 00217559-00217562 (អង់គ្លេស)។ (និយាយថា **មាស មុត** ជាកូនប្រសាររបស់ តាម៉ុក)។

[173] ឯកសារ **D22.2.182** ចម្លើយរបស់ **មាស មុត** ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក ឬអ្នកបាត់ខ្លួនក្នុងសង្គ្រាម ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០២ ["ពីដំបូង មាស មុត ត្រូវបានចាត់តាំងឲ្យធ្វើជាគ្រូពេទ្យនៅស្រុកអង្គជ័យ តំបន់១៣ ក្នុងឆ្នាំ១៩៧០"]។

[174] ឯកសារ **D22.2.182** ចម្លើយរបស់ **មាស មុត** ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក ឬអ្នកបាត់ខ្លួនក្នុងសង្គ្រាម ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០២ ["នៅចុងឆ្នាំ១៩៧០ ឬដើមឆ្នាំ១៩៧១ **មាស មុត** បានក្លាយជាមេបញ្ជាការរងយោធាស្រុកអង្គជ័យ នៅពេលនោះមានកងទ័ពប្រហែល២០០នាក់ ក្នុងស្រុក"]។

[175] ឯកសារ **D114/297.1.22** ម៉ុង វេត ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង ០៩.៥៩.៣៨-១០.០៣.១៤ ["ពី៧៣ មកដល់ ៧៥ អាហ្នឹង បងមុត គាត់ជាលេខ បងសោម អនុ។ ដល់ពេល **មុត** ឡើងទៅនៅកងពលទី៣ ទើបបងសោម ឡើងអនុវិញ"]។ ឯកសារ **D54/62 ម៉ុង វេត** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ["ឆ.១៥ នៅពេលដែលខ្ញុំចូលបដិវត្តឆ្នាំ១៩៧៣ ខ្ញុំបានឃើញ **មុត** (គាត់) នៅគណៈតំបន់រួចហើយ"]។

[176] ឯកសារ **D54/60.2 ម៉ុង វេត** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ["តា **មុត** នៅគណៈតំបន់១៣ រួចហើយ"]។

[177] ឯកសារ **D54/110 លុន សេង** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ["ឆ.២៧ **មាស មុត** ជាសមាជិកពេញសិទ្ធិរបស់បក្សពីព្រោះគាត់ចូលបដិវត្តតាំងពីយូរណាស់មកហើយ តាំងពីឆ្នាំ១៩៦០"]។

50. នៅឆ្នាំ១៩៧៣ គាត់ត្រូវបានតែងតាំងជាលេខាកងពលធំលេខ ៣ នៃភូមិភាគនិរតី[178]។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គាត់ជាលេខាកងពលធំលេខ ១៦៤ នៃកងទ័ពបដិវត្តកម្ពុជា។

## តួនាទីរបស់ មាស មុត

51. ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ **មាស មុត** គឺជាលេខាកងពល១៦៤ នៃកងទ័ពបដិវត្តកម្ពុជា និងជាមេបញ្ជាការកងទ័ពជើងទឹករបស់កងទ័ពបដិវត្តកម្ពុជា។ **មាស មុត** ជាសមាជិកគណៈមជ្ឈិម[179]។ បន្ថែមលើតួនាទីផ្នែកយោធា និងផ្នែកបក្ស **មាស មុត** បានកាន់កាប់ក្រុងកំពង់សោម តំបន់ជុំវិញ និងបណ្តាកោះនានា។

52. សមាជិកគណៈមជ្ឈិមបក្ស មានសមាជិកពេញសិទ្ធិ សមាជិកបម្រុង។ សមាជិកទាំងនេះយកចេញពីរដ្ឋមន្ត្រី លេខាភូមិភាគ តំបន់ និងលេខាកងពល។ យោងតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ភារកិច្ច ការទទួលខុសត្រូវរបស់សមាជិកគណៈមជ្ឈិមបក្ស គឺស្ថិតក្នុងចំណោមភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗ រួមមាន អនុវត្តមាគ៌ានយោបាយបក្ស ណែនាំគណៈកម្មាធិការភូមិភាគ និងតំបន់ ឲ្យអនុវត្តសកម្មភាពនានា ស្របតាមមាគ៌ានយោបាយរបស់បក្ស និងគ្រប់គ្រង និងចាត់តាំងកម្មាភិបាល និងសមាជិកបក្ស ឲ្យបានច្បាស់លាស់ និងឲ្យជាប់ជានិច្ចនូវប្រវត្តិរូប ជំហរនយោបាយ និងអង្គការចាត់តាំង[180]។

---

[178] អត្ថបទទស្សនាវដ្តីស្វែងរកការពិត មានចំណងជើងថា *ខ្ញុំចង់បានយុត្តិធម៌* **D1.3.7.9**, ចុះថ្ងៃទី ខែសីហា ឆ្នាំ២០០០ លេខចេញផ្សាយ ៨ ត្រង់ ERN 00204275, ERN 00204272-00204275 (អង់គ្លេស)។

[179] ឯកសារ **D1.3.33.15** កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ["គណៈកម្មាធិការមជ្ឈិមបក្សមានសមាជិកប្រមាណជា៣០នាក់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់ទេ។ ខ្ញុំចាំដូចជា **មាស មុត** កូនប្រសាររបស់តាម៉ុក"]។

[180] ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្ស ខែមករា ឆ្នាំ១៩៧៦ មាត្រា ២៣។

53. **មាស មុត** គឺជាលេខាកងពលលេខ ១៦៤ នៃកងទ័ពបដិវត្តកម្ពុជាដែលមានមូលដ្ឋាននៅកំពង់សោម រាម និង កំពត[181]។ គាត់ជាលេខាកងពលធំលេខ ១៦៤ យ៉ាងហោចណាស់ក៏ចាប់ពីខែមករា ឆ្នាំ ១៩៧៦[182] រហូតដល់យ៉ាងហោចណាស់ខែមេសា ឆ្នាំ១៩៧៨[183]។

54. បន្ថែមទៅលើតួនាទីរបស់គាត់ជាលេខាកងពលលេខ១៦៤ **មាស មុត** ជាសមាជិកនៃគណៈមជ្ឈិម នៃបក្សកុម្មុយនីស្តកម្ពុជា[184] ឬជាសមាជិកនៃគណៈជំនួយការនៃគណៈមជ្ឈិមនៃបក្សកុម្មុយនីស្ត កម្ពុជា[185]។ សមាជិកនៃគណៈជំនួយការមាន "ការទទួលខុសត្រូវផ្នែកនយោបាយ" នៅក្នុងបក្ស កុម្មុយនីស្តកម្ពុជា[186] ហើយមានសិទ្ធិក្នុងការទទួលបាននូវការហ្វឹកហាត់នៅមន្ទីរ៨៧០ ជាមួយ សមាជិកគណៈមជ្ឈិម[187]។

## ការដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

[181] សំដីរបស់**កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.7** ចុះថ្ងៃទី 4 ខែមិថុនា 1999, ERN 00089673-00089678 (ភាសាខ្មែរ)។ សំដីរបស់ **កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.15** ចុះថ្ងៃទី 13 ខែធ្នូ, ERN 00156751, ERN 00156741-00156751 (ភាសាអង់គ្លេស)។ អត្ថបទកាសែត ដោយ Erika KINETZ and YUN Samean មានចំណងជើងថា ទុកអតីតកាល ឱ្យនៅក្នុងអតីតកាល៖ អតីតមេដឹកនាំខ្មែរក្រហម **មាស មុត** ផ្គុះបញ្ចាំងពីជីវិត តុលាការ និងយុត្តិធម៌, ចុះថ្ងៃទី 1-2 ខែមីនា 2008, ERN 00165820-00165822 (អង់គ្លេស)។ សម្ភីរបស់ **មាស មុត, D1.3.33.16** ចុះថ្ងៃទី 20 ខែកក្កដា 2001, ERN 00089661-00089662 (អង់គ្លេស) (ទទួលស្គាល់ថា គាត់ជាមេបញ្ជាការរបស់កងពលនៃ ក.ប.ក មួយ)។ សំដីរបស់ សាក្សី ក.ស.ព-00138 កំណត់ត្រាសម្ភាសន៍របស់ ក.ស.ព, **D1.3.13.11**, ចុះថ្ងៃទី 12 ខែសីហា 2008, ERN 00217564, ERN 00217563-00217566 (អង់គ្លេស) (បង្ហាញថា **មាស មុត** ជាប្រធាន កងពល ១៦៤)។ សំដីរបស់សាក្សី ក.ស.ព-00138 កំណត់ត្រាសម្ភាសន៍របស់ ក.ស.ព, **D1.3.13.11,** ចុះថ្ងៃទី 12 ខែសីហា 2008, ERN 00217565, ERN00217563-00217566 (អង់គ្លេស)។ (និយាយថា មូលដ្ឋានកងទ័ពជើងទឹកសំខាន់ និងទីបញ្ជាការកងពលមានទីតាំងនៅរាម)។

[182] របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី 4 ខែមករា 1976, **D114/27.1.7**, ERN 00160081-00160081 (ខ្មែរ) (សរសេរថា "សមមិត្ត **មុត**" ជាប្រធានកងពល១៦៤)។ របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ, **D1.3.30.2** ចុះថ្ងៃទី 5 ខែមករា 1976, ERN 00021446-00021446 (ភាសាខ្មែរ)។

[183] របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ, **D1.3.30.25** ចុះថ្ងៃទី 1 ខែមេសា 1978, ERN 00017026-00017026 (ភាសាខ្មែរ)។

[184] សំដីរបស់ **ខៀវ សំផន** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.15** ចុះថ្ងៃទី 13 ខែធ្នូ, ERN 00156751, ERN 00156741-00156751 (អង់គ្លេស)។

[185] សំដីរបស់ **កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.13** ចុះថ្ងៃទី 4 ខែធ្នូ 2007 ERN 00154911, ERN 00154906-00154913 (អង់គ្លេស)។សំដីរបស់ **កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.10**ចុះថ្ងៃទី 2 ខែមិថុនា 2008 ERN 00195577, ERN 00195571-00195579 (អង់គ្លេស)។

[186] សំដីរបស់ **កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.10**ចុះថ្ងៃទី 2 ខែមិថុនា 2008 ERN 00195577, ERN 00195571-00195579 (អង់គ្លេស)។

[187] សំដីរបស់ **កាំងហ្គិច អ៊ាវ ហៅ ឌុច** ដែលស្រង់ដោយ ក.ស.ច.ស, **D1.3.33.13** ចុះថ្ងៃទី4 ខែធ្នូ ឆ្នាំ២00៧ ត្រង់ ERN 00154911, ERN 00154906-00154913 (អង់គ្លេស)។

55. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ **Mark Harmon** បានជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំងនឹង **មាស មុត** ដោយកំបាំងមុខ[188] នូវបទល្មើសអមដោយឧបសម្ពន្ធ[189] ដូចខាងក្រោម៖

**ការរំលោភបំពានមាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦**

ក-ការសម្លាប់នៅមន្ទីរសន្តិសុខ

ខ-ការបោសម្អាត ចំពោះអ្នកដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជនក្បត់នៅកំពង់សោម ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១

គ-ការបោសសម្អាតកម្មាភិបាលកងពល១១៧ និងតំបន់៥០៥ នៅខេត្តក្រចេះ ដែលបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១

ឃ-ការសម្លាប់ជនស៊ីវិលវៀតណាម និងថៃ (អ្នកនេសាទ និងជនភៀសខ្លួន) និងបរទេសផ្សេងៗទៀត នៅដែនសមុទ្រ និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជាអធិបតេយ្យភាពរបស់ខ្លួន។

ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣ថ្មី និងមាត្រា២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

-ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬសាសនាទៅលើជនជាតិវៀតណាម អតីតមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ ដែលត្រូវបានចាត់ទុកថាជាជនក្បត់ ឬខ្មាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ដូចជា ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើភាពថ្លៃថ្នូររបស់មនុស្ស ដោយសារការដកហូតមិនឲ្យមានអាហារគ្រប់គ្រាន់) ទាក់ទងនឹង៖

ក-មន្ទីរសន្តិសុខវត្តឥន្ទញាណ

ខ-ការបោសសម្អាត ចំពោះជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជនក្បត់នៅកំពង់សោម ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (នៅភ្នំពេញ)

---

[188] ឯកសារ **D128** ដីកាសម្រេចដាក់ **មាស មុត** ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។

[189] ឯកសារ **D128.1** ឧបសម្ពន្ធស្តីពីការជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំង **មាស មុត** ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។

គ-ការបោសសម្អាត ចំពោះកម្មាភិបាលកងពល១១៧ និងតំបន់៥០៥ នៅខេត្តក្រចេះ ដែលត្រូវបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (នៅភ្នំពេញ) និង

ឃ-ជនស៊ីវិលវៀតណាម និងថៃ (អ្នកនេសាទ និងជនភៀសខ្លួន) និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជាអធិបតេយ្យភាពរបស់ខ្លួន។

ឧក្រិដ្ឋកម្មទាំងនេះត្រូវផ្តន្ទាទោសតាមមាត្រា ៥ និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

**អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ**

ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើបាបដោយអមនុស្សធម៌ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម ទាក់ទងនឹង៖

ក-ការបោសសម្អាត ចំពោះជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជនក្បត់នៅកំពង់សោម ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (នៅភ្នំពេញ)

ខ-ការបោសសម្អាត ចំពោះកម្មាភិបាលកងពលលេខ១១៧ និងតំបន់៥០៥ នៅខេត្តក្រចេះ នៅខេត្តក្រចេះ ដែលត្រូវបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (នៅភ្នំពេញ) និង

គ-ជនស៊ីវិលវៀតណាម និងថៃ (អ្នកនេសាទ និងជនភៀសខ្លួន) និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជាអធិបតេយ្យភាពរបស់ខ្លួន។

ឧក្រិដ្ឋកម្មទាំងនេះត្រូវផ្តន្ទាទោសតាមមាត្រា ៦ និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

**ទម្រង់នៃការទទួលខុសត្រូវ**

តាមរយៈការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជម្រុញឲ្យមានបទឧក្រិដ្ឋ ដែលគាត់ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ពាក់ព័ន្ធនឹង៖

ក-ការផ្លាស់ទីប្រជាជនជាបន្តបន្ទាប់ពីតំបន់ជ្រជុំជន និងទីក្រុងទៅជនបទ និងពីជនបទ ទៅកន្លែងផ្សេងទៀត

ខ-ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន

គ-ការកសាង សមាសភាពមិនល្អ និងការសម្លាប់ខ្មាំង ទាំងនៅក្នុង និងនៅក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា

ឃ-ការដាក់មុខសញ្ញាលើក្រុមជាក់លាក់នានា ជាពិសេស ជនជាតិវៀតណាម និងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ រាប់បញ្ចូលទាំងមន្ត្រីស៊ីវិល ទាំងអតីតទាហាន និងគ្រួសាររបស់ពួកគេ។

ង-ការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍

## ការយល់ឃើញរបស់សហព្រះរាជអាជ្ញាជាតិ

## ការរួចផុតពីការទទួលខុសត្រូវ

56. គោលនយោបាយបោសសម្អាត ត្រូវបានស្តែងឡើងតាមរយៈសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលពាក់ព័ន្ធនឹងសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ។ ខ្លឹមសារនៃសេចក្តីសម្រេចដដែលនេះ ក៏បានកំណត់ច្បាស់ផងដែរទាក់ទងនឹងការបោសសម្អាតនៅក្នុងភូមិភាគ គឺក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវ "**អចិន្ត្រៃយ៍ភាគសម្រេច**"។[190] ដូចដែល ឌុច បានរៀបរាប់

[190] **D1/3/19/1** ឯកសារស្តីពីសេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ទំព័រ១។ **D6/1/1073** ឯកសារនៃការដាក់ចម្លើយរបស់ជនត្រូវចោទឈ្មោះ **កាំង ហ្កេកអ៊ាវ ហៅ ឌុច** ជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ដែលបានធ្វើការឆ្លើយតបទៅនឹងសំណួរជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២00៨ ទំព័រ៣។ **D6/1/91** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទឈ្មោះ **កាំង ហ្កេកអ៊ាវ ហៅ ឌុច** ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២00៨ ទំព័រ៣។ **D6/1/1060** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទឈ្មោះ **កាំង ហ្កេកអ៊ាវ ហៅ ឌុច** ចុះថ្ងៃទី0៥ ខែឧសភា ឆ្នាំ២00៨ ទំព័រ១៥។

ពាក់ព័ន្ធនឹងខ្លឹមសារនៃសេចក្ដីសម្រេចនេះថា "ឯកសារនេះមានលក្ខណៈជាប្រវត្តិសាស្ត្របញ្ជាក់ពីរបត់មួយនៃការចាប់ផ្ដើមការសម្រិតសម្រាំងផ្ទៃក្នុងបក្ស។"[191]

57. តាមការដឹកនាំតាមបែបកុម្មុយនីស្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្ដល់អំណាចឲ្យបក្សជាអ្នកមានអំណាចខ្ពស់បំផុត ពោលគឺ គណៈកម្មាធិការមជ្ឈិមបក្ស ដែលជាថ្នាក់ដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវធ្វើការសម្រេចលើការងារសំខាន់ៗពាក់ព័ន្ធនឹងជោគវាសនាប្រទេសជាតិ។គណៈកម្មាធិការនេះមានសមាសភាពប្រហែល ៣០រូប មានការប្រជុំជាទៀងទាត់(៦ខែម្ដង)។ ការអនុវត្តជាក់ស្ដែង សមាសភាពដែលត្រូវចូលរួមប្រជុំក៏មានការចូលរួមពីថ្នាក់ដឹកនាំគណៈភូមិភាគ និងគណៈតំបន់ផងដែរ។ ជាក់ស្ដែង អំណាចលើការសម្រេចនានាគឺស្ថិតនៅលើ គណៈកម្មាធិការអចិន្ត្រៃយ៍បក្សជាអ្នកសម្រេច ហើយដើរតួនាទីដ៏សំខាន់ក្នុងការដឹកនាំការងារប្រចាំថ្ងៃជំនួសគណៈកម្មាធិការមជ្ឈិមបក្ស។ គណៈកម្មាធិការនេះមានសមាសភាពចំនួន ៧រូប ដែលក្នុងនោះ ប៉ុល ពត គឺជាលេខាបក្ស និង នួន ជា គឺជាអនុលេខាបក្ស។

58. បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតឡើងតាំងពីមុនការកាន់អំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ មកម្ល៉េះ។ របបកម្ពុជាប្រជាធិបតេយ្យ ដឹកនាំតាមបែបកុម្មុយនីស្តដោយមានបក្សជាអ្នកដឹកនាំគ្រប់អ្វីៗទាំងអស់។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា មានគោលដៅធ្វើការបោសសម្អាត វណ្ណៈសក្តិភូមិ នាយទុន និងបញ្ញវន្ត ជាអាទិ៍ ហើយបានចាត់ទុកអ្នកទាំងនេះជាខ្មាំងដែលគេចោទថាធ្លាប់កេងប្រវ័ញ្ច និងជិះជាន់លើប្រជាជននាពេលកន្លងមក។ ដូច្នេះហើយទើបបក្សកុម្មុយនីស្តកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាការសងសឹកចំពោះអ្នកទាំងនោះ។

59. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏មានគោលនយោបាយបង្ក្រាប ដែលតម្រូវឲ្យកម្មាភិបាលនៃរបបនេះត្រូវតែអនុវត្តតាម បើមិនដូច្នោះទេកម្មាភិបាលដែលប្រឆាំងនឹងគោលនយោបាយត្រូវរងការបោះសម្អាត។ ការបង្ក្រាបនេះបានចាប់ផ្ដើមពីការចាប់ខ្លួនបណ្ដាមេដឹកនាំភូមិភាគមួយចំនួនយកទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ដូចជា កុយ ធួន, សោ ភឹម, វន វ៉េត, រស់ ញឹម, កង ចាប ហៅ សែ ជាដើម។

60. ការបង្ក្រាបកាន់តែរាលដាល លាតសន្ធឹងទូទាំងប្រទេស ជាពិសេសក្នុងឆ្នាំ១៩៧៦ ក្រោយពីមានសេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៦ ហើយស្របពេលដែលពាក្យ "ខ្មាំង" ត្រូវបានពង្រីកន័យ និងប្រើយ៉ាងទូលំទូលាយ។ បើសិនជានរណាម្នាក់ត្រូវបានចោទថា

[191] **D6/1/1063** កំណត់ហេតុនៃការស្ដួចម្លើយជនត្រូវចោទឈ្មោះ **កាំង ហ្គេកអ៊ាវ ហៅ ឌុច** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ទំព័រ៧។

ជាខ្លាំង អ្នកនោះនឹងត្រូវយកទៅសម្លាប់ចោលដោយគ្មានរកខុសត្រូវ និងឆ្លងកាត់នីតិវិធីតុលាការឡើយ។

## ការមិនអាចអនុវត្តយុត្តាធិការបុគ្គល

61. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានអាណត្តិ មានន័យថាមិនមែនជាតុលាការអចិន្ត្រៃយ៍ទេ។ អង្គជំនុំជម្រះនេះ មានលំនាំដូចជា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) តុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា (ICTR) និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL) ដែលបច្ចុប្បន្ន តុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា (ICTR) និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL) បានបញ្ចប់អាណត្តិរបស់ខ្លួនជាបណ្ដើរៗហើយ។

62. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើង ដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស **មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ** និង**ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត**ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។

63. រាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាស្ថាបនិកមួយនៃកិច្ចព្រមព្រៀង អាចមានឥទ្ធិពលលើដំណើរការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការបញ្ចប់អាណត្តិរបស់អង្គជំនុំជម្រះនេះ។ វិធីសាស្ត្រដែលអាចទទួលយកបានសម្រាប់ការបញ្ចប់អាណត្តិរបស់អង្គជំនុំជម្រះនេះ គឺការកម្រិតវិសាលភាពយុត្តាធិការបុគ្គល។ វិធីសាស្ត្របែបនេះ ត្រូវបានអនុវត្តនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា (ICTR) និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន (SCSL)។

64. ចំពោះស្ថានភាពជាក់ស្តែង នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិដែលជាស្ថាបនិករបស់តុលាការនេះ តាមរយៈវិធាន និងលិខិតុបករណ៍ជាច្រើន បានណែនាំឲ្យតុលាការនេះ ផ្តោតតែទៅលើមេដឹកនាំជាន់ខ្ពស់

ដែលសង្ស័យជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម នៅក្រោមយុត្តាធិការរបស់ខ្លួន[192]។ សេចក្តីសម្រេចលេខ៖២00៤ និងលេខ៖១៥0៣ របស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ បានអំពាវនាវតុលាការនិមួយៗ ធានាថា ក្នុងការពិនិត្យ និងបញ្ជាក់គាំទ្រលើការចោទប្រកាន់ថ្មី ដីកាចោទប្រកាន់ថ្មីនេះ ផ្តោតតែទៅលើមេដឹកនាំជាន់ខ្ពស់ ដែលសង្ស័យជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិការរបស់តុលាការពាក់ព័ន្ធ[193]។

65. ពាក់ព័ន្ធនឹងការកំណត់យុត្តាធិការបុគ្គល ចៅក្រមតុលាការ ICTY បានបង្កើតវិធានថ្មីៗជាច្រើន ដោយគោរពទៅតាមការណែនាំរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ដូចជា វិធាន១១ស្ទួន និងវិធាន២៨ក នៃវិធានស្តីពីភស្តុតាង និងនីតិវិធីរបស់តុលាការ ICTY។ ចៅក្រមមិនបារម្ភទេថា ការបង្កើតវិធាននេះ រំលោភលក្ខន្តិកៈរបស់តុលាការ និងកម្រិតឯករាជ្យភាពរបស់រដ្ឋអាជ្ញា។ ចាប់តាំងពីការបង្កើតវិធាននេះមក តុលាការ ICTY បានបង្វែរសំណុំរឿងទៅតុលាការថ្នាក់ជាតិ ដោយអនុវត្តស្របតាមការណែនាំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្នុងការប្រើវិធីសាស្ត្រពាក់ព័ន្ធនឹងការបិទតុលាការ[194]។

66. ចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មិនបានព្រមព្រៀងគ្នាផ្តល់យុត្តាធិការទៅតុលាការជាតិកម្ពុជា ក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ដោយមនុស្សដែលស្ថិតនៅក្នុងប្រភេទ "**មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ**" និង "**ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត**" ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និង

---

[192] សេចក្តីប្រកាសព័ត៌មាន "ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិអនុម័តយកវិធីសាស្ត្របង្វែរទៅតុលាការថ្នាក់ជាតិនូវករណីជាក់លាក់មួយចំនួនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអតីតយូហ្គោស្លាវី, UNSC ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00១, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៥0៣ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២00៣ កថាខណ្ឌ៦-៧, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៥៣៤ ថ្ងៃទី២៦ ខែមិនា ឆ្នាំ២00៤ កថាខណ្ឌ៥, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៩៦៦ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២0១0"។

[193] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិលេខ១៥៣៤, ដូចជើងទំព័រ ២៥ ខាងលើ កថាខណ្ឌ៥។

[194] ករណីរឿងក្តី *Stankovic* (IT-96-23/2-PT), RB សេចក្តីសម្រេចស្តីពីការបង្វិលសំណុំរឿង អនុលោមតាមវិធាន១១ស្ទួន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២00៥ កថាខណ្ឌ៩៦។ ករណីរឿងក្តី *D.Milosevic* (IT-98-29/1-PT), RB សេចក្តីសម្រេចស្តីពីការ បង្វិលសំណុំរឿង អនុលោមតាមវិធាន១១ស្ទួន ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២00៥ កថាខណ្ឌ២៤។ ករណីរឿងក្តី *Lukic & Lukic* (IT-98-23/1-PT), RB សេចក្តីសម្រេចស្តីពីការបង្វិលសំណុំរឿង អនុលោមតាមវិធាន១១ស្ទួន ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២00៧ កថាខណ្ឌ ១២៨-២៩។

ទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ឡើយ។

67. ចំណុចនេះបង្ហាញថា ស្ថាបនិកតុលាការអន្តរជាតិ អាចមានឥទ្ធិពលលើវិសាលភាពយុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ ដោយមិនធ្វើឲ្យប៉ះពាល់ដល់អនាគតិ និងឯករាជ្យភាពរបស់តុលាការឡើយ។ ការកម្រិតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺរាជរដ្ឋាភិបាលកម្ពុជាកំពុងតែដើរតួដូចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលក្រុមប្រឹក្សានេះបានអនុវត្តចំពោះតុលាការ ICTY ICTRនិង SCSL អញ្ចឹងដែរ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាជាតិជម្រុញឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងអង្គជំនុំជម្រះ ឲ្យធ្វើសកម្មភាពស្របតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមស្មារតីច្បាប់ អ.វ.ត.ក ដែលបានកំណត់យកតែ **មេដឹកនាំជាន់ខ្ពស់** និង**អ្នកទទួលខុសត្រូវខ្ពស់បំផុត** នៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ មកស៊ើបសួរ និងជំនុំជម្រះ។

68. គោលគំនិតរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រិតសម្រាំង "**មេដឹកនាំជាន់ខ្ពស់**" តែមួយចំនួនតូចប៉ុណ្ណោះ ដែលស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ពោលគឺចង់សំដៅតែទៅលើសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស រួមមាន ប៉ុល ពត, នួន ជា, សុន សេន, អៀង សារី, ខៀវ សំផន, កែ ពក, អៀង ធីរិទ្ធ, វ៉ាន់ រិទ្ធ និង អ៊ុង ជឿន ហៅ តា ម៉ុក។ ចំណែកឯ "**អ្នកទទួលខុសត្រូវខ្ពស់បំផុត**" គឺសំដៅតែ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ តែម្នាក់គត់ ដោយសារ ឌុច បានដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ មានស្វ័យភាពក្នុងការងារ និងមានអំណាចអនុវត្តជាក់ស្តែងផងដែរ។ ការកំណត់ចំនួនជនដែលត្រូវនាំយកមកកាត់ទោសដ៏តិចតួចនេះ ត្រូវបានលើកឡើងជាហូរហែរ និងមានការជជែកវែកញែកគ្នាយ៉ាងតឹងតែង នាពេលប្រជុំរដ្ឋសភាដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលក្នុងនោះបានបង្ហាញថាបុគ្គលដែលនឹងត្រូវស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក គឺមានតិចតួច មិនទូលំទូលាយទេ។

69. ដូច្នេះហើយ ក្នុងខែមីនា ឆ្នាំ១៩៩៩ អំឡុងពេលចរចាបង្កើតច្បាប់ អ.វ.ត.ក អ៊ុង ជឿន ហៅ តា ម៉ុក និង កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ននៅតុលាការយោធា ក្រោមការចោទប្រកាន់ពីបទ៖ ឧក្រិដ្ឋកម្មសង្គ្រាម ការបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង

ឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ ដែលត្រូវផ្តន្ទាទោសតាម មាត្រា ៦ និង ៨ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ២00១។

70. អ៊ុង ជឿន ហៅ តា ម៉ុក បានស្លាប់នៅខែកក្កដា ឆ្នាំ២00៦។ នៅថ្ងៃទី៣0 ខែកក្កដា ឆ្នាំ២00៧ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបាននាំខ្លួនពីតុលាការយោធាក្រុងភ្នំពេញ មកឃុំខ្លួននៅ អ.វ.ត.ក ដោយដីការបស់សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក[195]។

71. តាមរយៈបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលបាន អនុមតក្នុងសេចក្តីសម្រេចចិត្តលេខៈ៥៧/២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២00២ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ អង្គការសហប្រជាជាតិបានទទួលស្គាល់យ៉ាងជាក់លាក់ អំពីការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ មានន័យថា ត្រូវថ្លឹងថ្លែងរវាង "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ"។

72. ផ្តើមចេញពីការទទួលស្គាល់នេះ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការ សហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានសំដៅតែទៅលើបុគ្គលតែពីរប្រភេទប៉ុណ្ណោះមកធ្វើ ការវិនិច្ឆ័យសេចក្តីគឺ **មេដឹកនាំជាន់ខ្ពស់**កម្ពុជាប្រជាធិបតេយ្យ និង**ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត** ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី 0៦ ខែមករា ឆ្នាំ១៩៧៩។

73. ការពង្រីកវិសាលភាពពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល **មាស មុត** លើសពីវិសាលភាពនៃសំណុំរឿង លេខ 00១ និង00២ ដែលកំពុងមានស្រាប់នាពេលបច្ចុប្បន្ន នឹងអូសបន្លាយពេលវេលា និងចំណាយថវិកាដោយមិនចាំបាច់។ ម្យ៉ាងទៀត ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងរបប កម្ពុជាប្រជាធិបតេយ្យ ការឈឺចាប់របស់ជនរងគ្រោះដែលនៅរស់រានមានជីវិត និងយុត្តិធម៌ សម្រាប់ជនរងគ្រោះ អាចទទួលយកបានហើយ និងត្រូវគ្របដណ្តប់ដោយការជំនុំជម្រះសំណុំរឿង លេខ 00១ និង00២។

---

[195] ឯកសារ C4/2 ដីកាបង្គាប់ឲ្យឃុំខ្លួន **កាំង ហ្គេកអ៊ាវ ហៅ ឌុច** ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២00៧។

74. សរុបមក សហព្រះរាជអាជ្ញាជាតិ នៅតែចាត់ទុកថា **មាស មុត** មិនស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ដូចបានកំណត់ក្នុងមាត្រា ១ នៃច្បាប់ អ.វ.ត.ក ឡើយ។

## IV. ដំណោះស្រាយដែលស្នើសុំ

75. អាស្រ័យដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាជាតិ សូមស្នើអោយ អង្គបុរេជំនុំជម្រះ សម្រេចលើកលែងការចោទប្រកាន់ **មាស មុត** ដោយហេតុថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គល លើ **មាស មុត** ឡើយ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |